ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ៥៨ ត្រីមាសទី០៣ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ១២-៨-២០២៦ | -ព្រះរាជក្រម នស/រកម/០៨២៦/០១៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ាន សម្រាប់សម្ភារៈអគារនិងសំណង់ | ៦៩៦៣ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៤៨ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ២រូប | ៧០១៣ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៤៩ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់មន្ត្រីរាជការ ៤រូប នៅក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់សាមីខ្លួន | ៧០១៥ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ លោកស្រី HONG LI ប្រធានគណៈកម្មការរៀបចំមហោស្រពភាពយន្តកម្ពុជា-អាស៊ី | ៧០១៧ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់សប្បុរសជន ២រូប | ៧០១៨ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ដល់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២រូប | ៧០១៩ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តមបណ្ឌិត Khammany Inthirath អតីតរដ្ឋមន្ត្រីក្រសួងថាមពល និងរ៉ែ និងជាអតីតអគ្គនាយកអគ្គិសនីឡាវ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ៧០២០ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ១៧រូប | ៧០២១ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៨៣រូប | ៧០២២ |
| ៥-៨-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៦/៧៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ២៣០អង្គ/រូប | ៧០២៦ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ៨-៧-២០២៦ | -អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពី ការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ) | ៧០៣១ |
| ១៤-៧-២០២៦ | -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៧០៣៤ |

១៤-៧-២០២៦ -អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧០៣៦

១៤-៧-២០២៦ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧០៣៨

២០-៧-២០២៦ -អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ ៧០៤០

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៣ អនក្រ.តត ស្ដីពី ការបញ្ចប់មុខតំណែងទីប្រឹក្សា ៧០៤២

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៤ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧០៤៤

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៥ អនក្រ.តត ស្ដីពី ការតែងតាំងទីប្រឹក្សា ៧០៤៦

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៦ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧០៤៨

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៧ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ ៧០៥០

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៨ អនក្រ.តត ស្ដីពី ការផ្ទេរយោធិនពលី មរណៈ ៧០៥២

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦០៩ អនក្រ.តត ស្ដីពី ការលុបឈ្មោះ នាយទាហាន ៧០៥៤

២១-៧-២០២៦ -អនុក្រឹត្យលេខ ៦១០ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៧០៥៦


## ២-សេចក្ដីសម្រេច


៦-៧-២០២៦ -សេចក្ដីសម្រេចលេខ ៨២ សសរ ស្ដីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ៧០៥៨

៨-៧-២០២៦ -សេចក្ដីសម្រេចលេខ ៨៣ សសរ ស្ដីពី ការតែងតាំងសមាសភាពគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ) ៧០៥៩


# III-ការិយាល័យបណ្ដាក្រសួង

## ១-រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន


៨-៥-២០២៦ -សេចក្ដីសម្រេចលេខ ០២១/២៦ រកព.សសរ ស្ដីពី ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តព្រះវិហារ ៧០៦២

៨-៥-២០២៦ -សេចក្ដីសម្រេចលេខ ០២២/២៦ រកព.សសរ ស្ដីពី ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តស្ទឹងត្រែង ៧០៦៥


## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


៦-១-២០២៦ -ប្រកាសលេខ ០០៥ ប្រក.កសក ស្ដីពី រូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧០៦៨


## ៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


១៧-២-២០២៦ -ប្រកាសលេខ ១០៦ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនឡាយ ថេកស្លាយ ឯ.ក បង្កើតរោងចក្រផលិតភួយ ៧០៨២

# ព្រះរាជក្រម

នស/រកម/០៨២៦/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ានសម្រាប់សម្ភារៈអគារនិងសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួល
## ទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ាន
## សម្រាប់សម្ភារៈអគារនិងសំណង់



**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ានសម្រាប់សម្ភារៈអគារ និងសំណង់ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចសម្រុះសម្រួលនេះ។

ថ្ងៃ ពុធ ១៤ រោច ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ពរល. ២៦០៤. ៩០២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ាន សម្រាប់សម្ភារៈអគារនិងសំណង់

រាជរដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) (ចាប់ពីពេលនេះតទៅ ហៅជារួមថា «បណ្តារដ្ឋសមាជិក» ឬម្យ៉ាងទៀតសម្រាប់ជាឯកត្តបុគ្គលហៅថា «រដ្ឋសមាជិក»)។

**គោលបំណង** ដើម្បីសម្រេចសមាហរណកម្មសេដ្ឋកិច្ចនិងបង្កើនពិពិធកម្មដែលជាលក្ខណៈពិសេសរបស់តំបន់ឱ្យទៅជាឱកាសសម្រាប់ការបំពេញបន្ថែមធុរកិច្ច ធ្វើឱ្យអាស៊ានកាន់តែមានសក្តានុពលនិងកាន់តែរឹងមាំតាមផ្នែកនីមួយៗក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងសេដ្ឋកិច្ចពិភពលោក ដូចមានចែងក្នុងធម្មនុញ្ញអាស៊ាន សេចក្តីថ្លែងការណ៍អំពីផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានដែលបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំអាស៊ាន នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី និងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០២៥ ដែលបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំអាស៊ាន នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

**ការកំណត់** ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅនៃការបង្កើតនូវអាស៊ានជាទីផ្សារតែមួយនិងផលិតកម្មជាមូលដ្ឋានដែលមានស្ថិរភាព មានភាពរុងរឿង ប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មសេដ្ឋកិច្ចដោយមានការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពសម្រាប់ការធ្វើពាណិជ្ជកម្មនិងវិនិយោគ ដែលបង្កើតឱ្យមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម និងការវិនិយោគ សម្របសម្រួលសម្រាប់ចលនារបស់អ្នកធុរកិច្ច អ្នកជំនាញ អ្នកមានទេពកោសល្យ និងពលករ និងលំហូរសេរីនូវមូលធនដែលជាគោលបំណងចុងក្រោយរបស់អាស៊ាន។

**ការរំលឹកឡើងវិញ** ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន(ATIGA) ដែលត្រូវបានចុះហត្ថលេខានាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ នៅទីក្រុងចាអាម ប្រទេសថៃ និងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកត្រូវបានចុះហត្ថលេខានាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដើម្បីសម្របសម្រួលដល់ការលុបបំបាត់របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងលើកកម្ពស់ការធ្វើពាណិជ្ជកម្មនៅក្នុងអាស៊ាន។

**ការទទួលស្គាល់** ថា ការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោម គឺជាមធ្យោបាយដ៏សំខាន់មួយនៃការកាត់បន្ថយរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ហើយថាការទទួលស្គាល់ទៅវិញទៅមកបែបនេះគឺផ្តោតជាពិសេសចំពោះធុរកិច្ចនៅក្នុងអាស៊ាន។

**ការគិតគូរដល់** កម្រិតខុសគ្នានៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដា វិញ្ញាបនបត្រកម្ម អធិការកិច្ច និងការវិភាគ ហើយនិងកម្រិតខុសគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្តារដ្ឋសមាជិក។

**បញ្ជាក់ឡើងវិញ** ថា ការប្តេជ្ញាចិត្តរបស់បណ្តារដ្ឋសមាជិក ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម(TBT) ត្រូវបានបញ្ជាក់យ៉ាងច្បាស់ឡើងវិញនៅក្នុង ATIGA និង[illegible]ស្គាល់ថា សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចរចាក្នុងការ[illegible]សម្រាប់ការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោមរបស់រដ្ឋសមាជិកនីមួយៗ [illegible]នីតិវិធីផ្សេងៗនូវក្នុងចំណោមនីតិវិធីសម្រាប់ការយកគំរូផលិតផល ការធ្វើតេស្ត ការធ្វើអធិការកិច្ច ការវាយ[illegible]ផ្ទៀងផ្ទាត់ និងការធានានូវភាពអនុលោម ការចុះបញ្ជី ការវាយតម្លៃទទួលស្គាល់ និងការអនុម័ត ក៏ដូចជា[illegible]នីតិវិធីទាំងនេះផងដែរ។

**ការចង់បាន** ដើម្បីបង្កើតកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកសម្រាប់លទ្ធផលនៃការវាយតម្លៃភាពអនុលោមសម្រាប់សម្ភារៈអគារនិងសំណង់ដើម្បីសម្របសម្រួលចលនាផ្នែកសម្ភារៈអគារនិងសំណង់នៅក្នុងអាស៊ាន។

**បានយល់ព្រម ដូចខាងក្រោម៖**

**មាត្រា១**
**និយមន័យ**

សម្រាប់គោលបំណងនៃកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ានសម្រាប់ផ្នែកសម្ភារៈអគារនិងសំណង់ (ចាប់ពីពេលនេះតទៅហៅថា «MRAតាមផ្នែក» ) ត្រូវអនុវត្តនិយមន័យខាងក្រោម៖

ក- **ការទទួលយក** សំដៅដល់ការប្រើប្រាស់របាយការណ៍តេស្តឬវិញ្ញាបនបត្រ ជាមូលដ្ឋានសម្រាប់សកម្មភាពបញ្ញត្តកម្ម ដូចជាការអនុម័តយល់ព្រម អាជ្ញាបណ្ណ និងការវាយតម្លៃភាពអនុលោមនៅក្រោយទីផ្សារ។

ខ- **ការវាយតម្លៃទទួលស្គាល់** សំដៅដល់សេចក្តីថ្លែងការណ៍មួយដែលចេញដោយអង្គភាពឯករាជ្យមួយបញ្ជាក់អះអាងពីសមត្ថភាពរបស់អង្គភាពវាយតម្លៃភាពអនុលោមមួយ ដើម្បីអនុវត្តការងារវាយតម្លៃភាពអនុលោមជាក់លាក់។

គ- **អង្គភាពវាយតម្លៃទទួលស្គាល់** សំដៅដល់អង្គភាពមួយដែលបានទទួលសិទ្ធិជាផ្លូវការដើម្បីអនុវត្តការវាយតម្លៃទទួលស្គាល់។

ឃ- **សម្ភារៈអគារនិងសំណង់** សំដៅដល់ប្រភេទ ទំហំ និងលក្ខណៈធម្មជាតិណាមួយនៃសម្ភារៈ-ទោះជាការចាប់ផ្តើម បណ្តោះអាសន្ន ពាក់កណ្តាលសម្រេច ឬសម្រេច ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសាងសង់។

ង- **វិញ្ញាបនបត្រកម្ម** សំដៅដល់នីតិវិធីមួយ ដែលភាគីទីបីផ្តល់ជាលាយលក្ខណ៍អក្សរ ឬការធានាផ្សេងទៀតថា ផលិតផលមួយ ដំណើរការ ឬសេវាកម្ម អនុលោមទៅតាមការតម្រូវដែលបានកំណត់។

ច- **ការវាយតម្លៃភាពអនុលោម** សំដៅដល់ការបកស្រាយថា ការតម្រូវដែលបានកំណត់ពាក់ព័ន្ធទៅនឹងផលិតផលមួយ ដំណើរការ ប្រព័ន្ធ បុគ្គល ឬអង្គភាពត្រូវបានបំពេញ។

ឆ- **អង្គភាពវាយតម្លៃភាពអនុលោម** (ចាប់ពីពេលនេះតទៅហៅថា «CABs») សំដៅដល់អង្គភាពមួយដែលអនុវត្តសេវាកម្មវាយតម្លៃភាពអនុលោម ដែលបំពេញទៅតាមការតម្រូវនៃសមត្ថភាពបច្ចេកទេសដែលបានកំណត់ក្នុងជំពូកក និងជំពូកង នៃឧបសម្ព័ន្ធ១។

ជ- **នីតិវិធីវាយតម្លៃភាពអនុលោម** សំដៅដល់នីតិវិធីណាមួយដែលបានប្រើដោយផ្ទាល់ឬដោយប្រយោល ដើម្បីកំណត់ថា ការតម្រូវពាក់ព័ន្ធនៅក្នុងបទប្បញ្ញតិបច្ចេកទេសឬស្តង់ដាត្រូវបានបំពេញ។

ឈ- **ចំណុចទំនាក់ទំនង** សំដៅដល់បុគ្គលមួយ មុខងារមួយ ឬអង្គភាពមួយ ដែលអ្នកនោះធ្វើការជាមួយនិងតាមរយៈបណ្តារដ្ឋសមាជិក នឹងធ្វើការផ្លាស់ប្តូរព័ត៌មាននិងប្រាស្រ័យទាក់ទងស្របតាមការតម្រូវនៃMRAតាមផ្នែកនេះ។

ញ- **អង្គភាពចាត់តាំង** សំដៅដល់អង្គភាពមួយដែលបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ឬបានទទួលសិទ្ធិពីរដ្ឋាភិបាល ដើម្បីចាត់តាំងCAB ព្យួរ ឬដកហូតនូវការចាត់តាំងរបស់ខ្លួន ឬលុបចោលជាស្ថាពរ នូវការព្យួរ ឬបើកឡើងវិញការចាត់តាំងរបស់ខ្លួន។

ដ- **ការចាត់តាំង** សំដៅដល់សិទ្ធិអំណាចផ្លូវរដ្ឋរបស់អង្គភាពវាយតម្លៃភាពអនុលោមមួយដើម្បីអនុវត្តសកម្មភាពវាយតម្លៃភាពអនុលោមដែលបានកំណត់។

ឋ- **អង្គភាពវាយតម្លៃភាពអនុលោមដែលបានចុះបញ្ជី** សំដៅដល់អង្គភាពវាយតម្លៃភាពអនុលោមក្នុងស្រុករបស់ខ្លួនឬអង្គភាពវាយតម្លៃភាពអនុលោមបរទេសដែលមានទីតាំងនៅក្នុងដែនដីរបស់រដ្ឋសមាជិកមួយ ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមការតម្រូវនៃMRAតាមផ្នែកនេះ។

ឌ- **ការទទួលស្គាល់លទ្ធផលវាយតម្លៃភាពអនុលោម** សំដៅដល់ការទទួលស្គាល់នូវសុពលភាពនៃលទ្ធផលវាយតម្លៃភាពអនុលោមដែលបានផ្តល់ដោយបុគ្គលឬអង្គភាពមួយផ្សេងទៀត។

ឍ- **អាជ្ញាធរបញ្ញត្តកម្ម** សំដៅដល់អង្គភាពមួយដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការត្រួតពិនិត្យការនាំចូល ការប្រើប្រាស់ ឬការលក់ផលិតផល នៅក្នុងយុត្តាធិការរបស់រដ្ឋសមាជិកមួយ ដែលអាចចាត់វិធានការអនុវត្តច្បាប់ដើម្បីធានាថាផលិតផលបានចរាចរលើទីផ្សារក្នុងយុត្តាធិការរបស់ខ្លួនអនុលោមតាមការតម្រូវផ្លូវច្បាប់ និង

ណ- **ស្តង់ដា** សំដៅដល់ឯកសារមួយដែលបានអនុម័តដោយអង្គភាពទទួលស្គាល់មួយ ដែលផ្តល់សម្រាប់ការប្រើប្រាស់ជារួមនិងប្រើប្រាស់ឡើងវិញ ជាក្បួន គោលការណ៍ណែនាំ ឬចរិតលក្ខណៈសម្រាប់ផលិតផល ឬដំណើរការពាក់ព័ន្ធនិងវិធីសាស្ត្រផលិតកម្ម ដែលផ្សារភ្ជាប់នឹងអនុលោមភាព គឺមិនមានជាលក្ខណៈបញ្ជា។ ឯកសារនេះអាចរួមបញ្ចូលឬដោះស្រាយដោយឡែកជាមួយនឹងវាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការដាក់ម៉ាក ឬការតម្រូវនៃស្លាកសញ្ញាទៅតាមការអនុវត្តរបស់អ្នកទាំងនោះទៅលើផលិតផលមួយ ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។

## មាត្រា២
## គោលបំណង

គោលបំណងនៃMRAតាមផ្នែកនេះ គឺជំរុញឱ្យមាននូវការទទួលស្គាល់គ្នាទៅវិញទៅមកនូវរបាយការណ៍តេស្តឬវិញ្ញាបនបត្រសម្រាប់សំណង់និងសម្ភារៈសាងសង់ ដែលចេញដោយCABs ដែលបានចុះបញ្ជី។

## មាត្រា៣
## វិសាលភាព

១- វិសាលភាពនៃMRAតាមផ្នែកនេះ គឺដើម្បីសម្របសម្រួលឱ្យមានការទទួលស្គាល់គ្នាទៅវិញទៅមកនូវលទ្ធផលវាយតម្លៃភាពអនុលោមសម្រាប់សម្ភារៈអគារនិងសំណង់ ដូចមានកំណត់ក្នុងបញ្ជីនៃឧបសម្ព័ន្ធក ស្តីពីបញ្ជីសម្ភារៈអគារនិងសំណង់ ស្ថិតក្រោមវិសាលភាពនៃMRAតាមផ្នែកនេះ (ចាប់ពីពេលនេះតទៅ ហៅថា «ឧបសម្ព័ន្ធក»)។

២- MRA តាមផ្នែកនេះ អនុវត្តសម្រាប់គ្រប់ករណីប្រឈម នៅពេលដែលរបាយការណ៍តេស្តឬវិញ្ញាបនបត្រ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់សកម្មភាពបញ្ញត្តកម្ម ដែលទាក់ទងនឹងសម្ភារៈអគារនិងសំណង់។

## មាត្រា៤
## បទប្បញ្ញត្តិទូទៅ

១- បក្សភាគីនីមួយៗត្រូវទទួលយករបាយការណ៍តេស្តឬវិញ្ញាបនបត្រ បានចេញដោយCABs ដែលបានចុះបញ្ជី។

២- នៅពេលដែលរបាយការណ៍តេស្តឬវិញ្ញាបនបត្រ ត្រូវបានចេញទាក់ទិននឹងយថាប្រភេទផលិតផលនៃសម្ភារៈអគារ និងសំណង់ របស់បណ្តារដ្ឋសមាជិកដែលត្រូវបាននាំចូល បណ្តារដ្ឋសមាជិកនាំចូលរក្សាសិទ្ធិផ្ទៀងផ្ទាត់លទ្ធផលវាយតម្លៃភាពអនុលោមនៃសម្ភារៈអគារនិងសំណង់នោះ។

៣- ក្នុងករណីអវត្តមានសុខដុមនីយកម្មស្តង់ដា រដ្ឋសមាជិកមួយដែលកំពុងស្វែងរកការនាំចេញសម្ភារៈអគារនិងសំណង់ទៅរដ្ឋសមាជិកនាំចូល ត្រូវអនុលោមតាមស្តង់ដារបស់រដ្ឋសមាជិកនាំចូលនោះ។

៤- តាមរយៈចំណុចទំនាក់ទំនងរបស់ខ្លួនបណ្តារដ្ឋសមាជិកត្រូវតែពង្រឹងនិងបង្កើនការខិតខំប្រឹងប្រែងចំពោះកិច្ចសហប្រតិបត្តិការដែលកំពុងមានវត្តមានសម្រាប់ការផ្លាស់ប្តូរព័ត៌មានអំពីការតម្រូវបញ្ញត្តកម្ម របបនិងនីតិវិធីនៃការវាយតម្លៃភាពអនុលោមរបស់ខ្លួន និងតាមរយៈការកសាងទំនុកចិត្តណាមួយ ដូចខាងក្រោម៖

ក- ការបង្កើតឬការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ក្នុងការធ្វើព្យាសកម្ម ការធ្វើតេស្តវិញ្ញាបនបត្រកម្ម និងការវាយតម្លៃទទួលស្គាល់ ដើម្បីឆ្លើយតបទៅនឹងការតម្រូវពាក់ព័ន្ធជាលក្ខណៈអន្តរជាតិសម្រាប់សម្ភារៈអគារ និងសំណង់។

ខ- ការសហប្រតិបត្តិការនិងការចូលរួមក្នុងការធ្វើតេស្តវាស់ស្ទង់សមត្ថភាពសម្រាប់សម្ភារៈអគារនិងសំណង់ ឬ

គ- ការចូលរួមយ៉ាងសកម្មក្នុងការរៀបចំចាត់ចែងពាក់ព័ន្ធដោយអង្គភាពជំនាញថ្នាក់តំបន់និងអន្តរជាតិ។

៥- ប្រសិនបើឯកសារមួយត្រូវបានចេញសម្រាប់គោលបំណងនៃការផ្លាស់ប្តូរព័ត៌មាន ការផ្ទៀងផ្ទាត់ ការផ្តល់ភស្តុតាង និងសកម្មភាពផ្សេងទៀតដែលកើតចេញពីកាតព្វកិច្ចស្ថិតនៅក្រោមMRAតាមផ្នែកនេះ មិនមែនជាភាសាអង់គ្លេស ឯកសារនោះនឹងត្រូវបកប្រែជាភាសាអង់គ្លេស។

## មាត្រា៥
## គណៈកម្មការចម្រុះតាមផ្នែក

១- គណៈកម្មការចម្រុះតាមផ្នែកមួយ(ចាប់ពីពេលនេះតទៅ ហៅថា «JSC») ត្រូវតែបានបង្កើត ហើយគណៈកម្មការចម្រុះតាមផ្នែកនោះត្រូវតែទទួលខុសត្រូវធ្វើឱ្យមុខងាររបស់MRAតាមផ្នែកនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

២- JSC ត្រូវមានតំណាងឧត្តមមន្ត្រីមកពីអាជ្ញាធរបញ្ញត្តកម្មនៃរដ្ឋសមាជិកនីមួយៗ។ បណ្តារដ្ឋសមាជិកដែលមិនមានអាជ្ញាធរបញ្ញត្តកម្មដូចមានចែងនៅក្នុងចំណុចឈ នៃមាត្រា១ ត្រូវចាត់តាំងអង្គភាពមួយជាអាជ្ញាធរបញ្ញត្តកម្មសម្រាប់គោលបំណងនៃMRAតាមផ្នែកនេះ។ តំណាងឧត្តមមន្ត្រី អាចត្រូវបានអមដំណើរដោយប្រតិភូរបស់ខ្លួន នៅក្នុងកិច្ចប្រជុំរបស់JSC។

៣- JSC ត្រូវតែទទួលខុសត្រូវ ដូចខាងក្រោម៖

ក- ការធ្វើអត្តសញ្ញាណកម្មនិងការចុះបញ្ជីស្តង់ដាសម្រាប់ផលិតផលជាក់លាក់

ខ- ការចុះបញ្ជី ការព្យួរ ការលុបចោល និងការផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេសរបស់CABs ស្របតាមឧបសម្ព័ន្ធខ នៃនីតិវិធីនិងការតម្រូវទាក់ទិននឹងការចុះបញ្ជី ការព្យួរ ការលុបចោល ការផ្ទៀងផ្ទាត់ និងសមត្ថភាពបច្ចេកទេសសម្រាប់CABs (ចាប់ពីពេលនេះតទៅ ហៅថា «ឧបសម្ព័ន្ធខ»)។

គ- ការផ្តល់វេទិកាសម្រាប់ការពិភាក្សាពីបញ្ហានានាដែលអាចកើតឡើងទាក់ទិននឹងការប្រតិបត្តិMRAតាមផ្នែកនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឃ- ការស្នើសុំធ្វើវិសោធនកម្មលើប្រការនានានៃMRAតាមផ្នែកនេះ រួមបញ្ចូលទាំងឧបសម្ព័ន្ធនានារបស់វានិងការស្នើសុំឧបសម្ព័ន្ធបន្ថែម។

ង- ការពិចារណាវិធានការគោលនយោបាយនានាដើម្បីលើកកម្ពស់ការប្រតិបត្តិMRAតាមផ្នែកនេះ។

ច- ការបង្កើតវិធាននិងនីតិវិធីនានាផ្ទាល់របស់ខ្លួន និង

ឆ- ការពិចារណាលើបញ្ហាផ្សេងណាមួយនិងការចាត់វិធានការសមស្របទាក់ទិននឹងការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនៃMRAតាមផ្នែកនេះ។

៤- JSC ត្រូវព្យាយាមរៀបចំកិច្ចប្រជុំយ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយឆ្នាំដើម្បីបំពេញភារកិច្ច និងទំនួលខុសត្រូវរបស់ខ្លួន។ សេចក្តីសម្រេចរបស់JSC ត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នា។

## មាត្រា៦
## អង្គភាពចាត់តាំង

១- បណ្តារដ្ឋសមាជិកត្រូវធ្វើអត្តសញ្ញាណកម្មនិងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ានអំពីឈ្មោះអង្គភាពចាត់តាំងរបស់ខ្លួន និងធ្វើបច្ចុប្បន្នភាពទៅលេខាធិការដ្ឋានអាស៊ានសម្រាប់ការផ្លាស់ប្តូរណាមួយ។

២- បណ្តារដ្ឋសមាជិកត្រូវធានាថា អង្គភាពចាត់តាំងរបស់ខ្លួនមានសិទ្ធិអំណាចនិងសមត្ថភាពក្នុងដែនដីរបស់ខ្លួនដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលបានតម្រូវនៅក្រោមMRAតាមផ្នែកនេះ។

៣- អង្គភាពចាត់តាំងត្រូវតាមដានជាប្រចាំនូវCABs ដែលបានចុះបញ្ជី ស្របតាមប្រការនានានៃMRAតាមផ្នែកនេះ ដើម្បីធានាថា អង្គភាពទាំងនោះសុទ្ធតែមានសមត្ថភាពនិងនៅតែរក្សាសមត្ថភាពក្នុងការវាយតម្លៃដោយត្រឹមត្រូវនូវភាពអនុលោមនៃផលិតផលឬដំណើរការ តាមតែអាចធ្វើទៅបាននិងសកម្មភាពផ្សេងទៀតដែលគ្របដណ្តប់ដោយMRA តាមផ្នែកនេះ។

៤- អាជ្ញាធរបញ្ញត្តកម្មត្រូវពិគ្រោះយោបល់ជាមួយអង្គភាពចាត់តាំងពាក់ព័ន្ធ ដើម្បីធានាថា គ្រប់ការតម្រូវបច្ចេកទេសទាំងអស់ដែលបានធ្វើអត្តសញ្ញាណកម្មនៅក្នុងMRAតាមផ្នែកនេះ ត្រូវបានបកស្រាយយ៉ាងពេញចិត្ត។

## មាត្រា៧
## អង្គភាពវាយតម្លៃភាពអនុលោម

១- នីតិវិធីនិងការតម្រូវទាក់ទិននឹងការចុះបញ្ជី ការព្យួរ ការលុបចោល ការផ្ទៀងផ្ទាត់ និងសមត្ថភាពបច្ចេកទេសរបស់ CABs ត្រូវតែអនុលោមតាមឧបសម្ព័ន្ធខ។

២- CABs ដែលបានអនុម័តទទួលយក ត្រូវតែបានចុះបញ្ជីក្នុងឧបសម្ព័ន្ធគ ស្តីពីបញ្ជីឈ្មោះអង្គភាពវាយតម្លៃភាពអនុលោម (ចាប់ពីពេលនេះតទៅ ហៅថា «ឧបសម្ព័ន្ធគ») និងត្រូវតែបានធ្វើបច្ចុប្បន្នភាពដោយលេខាធិការដ្ឋានអាស៊ាន។

## មាត្រា៨
## ការរក្សាសិទ្ធិរបស់អាជ្ញាធរបញ្ញត្តកម្ម

១- គ្មាន[illegible]ងMRA តាមផ្នែកនេះ ត្រូវបានស្ថាបនាដើម្បីកំណត់សិទ្ធិអំណាចរបស់រដ្ឋសមាជិកមួយ ដើម្បីកំណត់កម្រិតនៃ[illegible]វាតាមរយៈនីតិប្បញ្ញត្តិ បទប្បញ្ញត្តិ និងវិធានការរដ្ឋបាលនានារបស់ខ្លួនឡើយ។ វាត្រូវពិចារណាឱ្យបាន[illegible]សមស្របតាម[illegible]

ក- សុវត្ថិភាព។

ខ- ការការពារជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ។

គ- បរិស្ថាន និង

ឃ- អ្នកប្រើប្រាស់។

២- គ្មានអ្វីនៅក្នុងMRAតាមផ្នែកនេះ ត្រូវបានស្ថាបនាសម្រាប់កំណត់សិទ្ធិអំណាចរបស់អាជ្ញាធរបញ្ញត្តកម្ម ដើម្បីចាត់គ្រប់វិធានការសមស្របនិងជាបន្ទាន់ នៅពេលដែលវារកឃើញថាសម្ភារៈអគារនិងសំណង់អាចៈ

ក- ប៉ះពាលដល់សុខភាពឬសុវត្ថិភាពរបស់បុគ្គលក្នុងដែនដីរបស់ខ្លួន។

ខ- មិនបំពេញតាមនីតិប្បញ្ញត្តិ បទប្បញ្ញត្តិ ឬវិធានការរដ្ឋបាលនានា ក្នុងវិសាលភាពនៃMRAតាមផ្នែកនេះ ឬ

គ- បើមិនដូច្នោះទេ មិនបានបំពេញទៅតាមការតម្រូវមួយនៅក្នុងវិសាលភាពនៃMRAតាមផ្នែកនេះ។

៣- ប្រសិនបើអាជ្ញាធរបញ្ញត្តកម្មចាត់វិធានការបែបនេះ វាត្រូវតែជូនដំណឹងដល់អាជ្ញាធរបញ្ញត្តកម្មនៃបណ្តារដ្ឋសមាជិកដទៃទៀត អំពីវិធានដែលបានអនុវត្ត ហើយវាត្រូវផ្តល់មូលហេតុសម្រាប់ការចាត់វិធានការបែបនោះឱ្យបានទាន់ពេលវេលា។

## មាត្រា៩
## ការសម្ងាត់

១- បណ្តារដ្ឋសមាជិកត្រូវរក្សាការសម្ងាត់ពីព័ត៌មានដែលបានផ្លាស់ប្តូរក្រោមMRAតាមផ្នែកនេះ ទៅតាមកម្រិតដែលបានអនុញ្ញាតក្រោមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។

២- បណ្តារដ្ឋសមាជិកត្រូវតែចាត់វិធានការប្រុងប្រយ័ត្នសមហេតុផលដែលចាំបាច់ ដើម្បីការពារព័ត៌មានដែលបានផ្លាស់ប្តូរក្រោមMRAតាមផ្នែកនេះ ចេញពីការបញ្ចេញព័ត៌មានដោយមិនមានការអនុញ្ញាត។

## មាត្រា១០
## ការដោះស្រាយវិវាទ

១- បណ្តារដ្ឋសមាជិកត្រូវព្យាយាមគ្រប់ពេលវេលាដើម្បីឯកភាពលើការបកស្រាយឬការអនុវត្តMRAតាមផ្នែកនេះ និងត្រូវខិតខំប្រឹងប្រែងតាមរយៈការប្រាស្រ័យទាក់ទង ការសន្ទនា ការពិគ្រោះយោបល់ និងការសហការ ដើម្បីឈានទៅរកដំណោះស្រាយមួយឱ្យពេញចិត្តទៅវិញទៅមកលើបញ្ហាណាមួយដែលអាចប៉ះពាលដល់ការអនុវត្តMRAតាមផ្នែកនេះ។

២- នៅក្នុងករណីដែលបណ្តារដ្ឋសមាជិក មិនអាចឈានទៅរកដំណោះស្រាយឱ្យពេញចិត្តទៅវិញទៅមកបាន ពិធីសារអាស៊ានស្តីពីយន្តការដោះស្រាយវិវាទដែលបានចុះហត្ថលេខានាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឬឯកសារស្នងពិធីសារនេះ ត្រូវយកមកអនុវត្តដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងការបកស្រាយ ឬការប្រតិបត្តិនៃប្រការណាមួយនៅក្រោមMRAតាមផ្នែកនេះ។

## មាត្រា១១
## ការតម្កល់ឯកសារ

MRAតាមផ្នែកនេះ ត្រូវបានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជាបន្ទាន់នូវឯកសារដែលមានបញ្ជាក់ច្បាប់ថតចម្លង ទៅរដ្ឋសមាជិកនីមួយៗ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា១២
## វិសោធនកម្ម

១- ប្រការទាំងឡាយណានៃMRAតាមផ្នែកនេះ អាចធ្វើវិសោធនកម្មបាន លុះត្រាតែមានការព្រមព្រៀងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សររបស់បណ្ដារដ្ឋសមាជិកតែប៉ុណ្ណោះ។ ខ្លឹមសារវិសោធនកម្មណាមួយត្រូវតែចូលជាធរមានទៅតាមកាលបរិច្ឆេទនោះ ដែលត្រូវតែបានព្រមព្រៀងគ្នាទៅវិញទៅមក អាស្រ័យដោយបណ្ដារដ្ឋសមាជិក។

២- ទោះបីជាមានកថាខណ្ឌទី១នៃមាត្រានេះក៏ដោយ ការធ្វើវិសោធនកម្មអាចធ្វើបានចំពោះ៖

ក- ឧបសម្ព័ន្ធក ជាកម្មវត្ថុសម្រាប់ការឯកភាពពីគណៈកម្មាធិការពិគ្រោះយោបល់អាស៊ានសម្រាប់ស្ដង់ដានិងគុណភាព ( ACCSQ ) និង

ខ- ឧបសម្ព័ន្ធខនិងឧបសម្ព័ន្ធគ ជាកម្មវត្ថុសម្រាប់ការឯកភាពពីក្រុមការងារអាស៊ានផ្នែកសម្ភារៈអគារនិងសំណង់។

សេចក្ដីវិសោធនកម្មទាំងនេះត្រូវតែបានរៀបចំជាឧបសម្ព័ន្ធចំពោះMRA តាមផ្នែកនេះ ហើយត្រូវជាផ្នែកគួបផ្សំនៃMRA តាមផ្នែកនេះ។

## មាត្រា១៣
## អវសានប្បញ្ញត្តិ

១- MRA តាមផ្នែកនេះអាចត្រូវបានពិនិត្យឡើងវិញដោយបណ្ដារដ្ឋសមាជិកក្នុងគោលបំណងនៃការបំពេញគោលដៅរបស់MRA តាមផ្នែកនេះ។

២- បណ្ដារដ្ឋសមាជិកមិនត្រូវមានឧបម្រុងចំពោះប្រការណាមួយនៃMRAតាមផ្នែកនេះឡើយ។

៣- MRAតាមផ្នែកនេះត្រូវតែចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបណ្ដារដ្ឋសមាជិកបានជូនដំណឹងទៅអគ្គលេខាធិការដ្ឋានអាស៊ាន អំពីការបញ្ចប់ការតម្រូវផ្ទៃក្នុងរបស់ខ្លួន ឬនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ឬពេលណាមួយមុនពេលកំណត់។

៤- ក្នុងករណីដែលរដ្ឋសមាជិកមួយជូនដំណឹងក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ MRAតាមផ្នែកនេះចូលជាធរមានសម្រាប់រដ្ឋសមាជិកនោះនៅរយៈពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់ខ្លួន។

៥- អគ្គលេខាធិការដ្ឋានអាស៊ាន ត្រូវតែជូនដំណឹងជាបន្ទាន់ដល់បណ្ដារដ្ឋសមាជិកអំពីការជូនដំណឹងនោះ ដោយផ្អែកតាមកថាខណ្ឌទី៣និង៤។

ក្នុងភាពជាសាក្សី ហត្ថលេខីខាងក្រោមត្រូវបានផ្ដល់សិទ្ធិពេញលេញដោយរដ្ឋាភិបាលរៀងៗខ្លួន ឱ្យចុះហត្ថលេខាលើMRA នេះ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៩ ខែមីនា ក្នុងឆ្នាំ២០២៤ ជាឯកសារច្បាប់ដើមមួយគត់ជាភាសាអង់គ្លេស។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

តំណាងរាជរដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម

DATO DR. AMIN LIEW ABDULLAH

រដ្ឋមន្ត្រីនៃការិយាល័យនាយករដ្ឋមន្ត្រី និងជា

រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទី២

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

CHAM NIMUL

រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

ZULKIFLI HASAN

រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

MALAITHONG KOMMASITH

រដ្ឋមន្ត្រីឧស្សាហកម្មនិងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី

TENGKU DATUK SERI UTAMA ZAFRUL TENGKU ABDUL AZIZ

រដ្ឋមន្ត្រីវិនិយោគ ពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

KAN ZAW

រដ្ឋមន្ត្រីសហព័ន្ធសម្រាប់ទំនាក់ទំនងសេដ្ឋកិច្ច បរទេស និងវិនិយោគ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

តំណាងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ALFREDO E. PASCUAL

រដ្ឋលេខាធិការពាណិជ្ជកម្មនិងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

GAN KIM YONG

រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលព្រះរាជាណាចក្រថៃ

PHUMTHAM WECHAYACHAI

ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

NGUYEN HONG DIEN

រដ្ឋមន្ត្រីឧស្សាហកម្មនិងពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឧបសម្ព័ន្ធក**

**បញ្ជីសម្ភារៈអគារនិងសំណង់ស្ថិតក្រោមវិសាលភាពនៃ**

MRA **តាមផ្នែកនេះ**

១- បញ្ជីសម្ភារៈអគារនិងសំណង់ស្ថិតក្រោមវិសាលភាពនៃMRAតាមផ្នែកនេះ មានដូចខាងក្រោម៖

| ល.រ. | HS Code | បរិយាយមុខទំនិញ |
|---|---|---|
| ១ | **25.23** | ស៊ីម៉ងត៍ផតឡែន ស៊ីម៉ងត៍មានសារធាតុអាលុយមីញ៉ូម ស៊ីម៉ងត៍រីង ស៊ីម៉ងត៍ស៊ុលផាតពិសេស និងស៊ីម៉ងត៍ទឹកស្រដៀងនេះ បើទោះជាលាយពណ៌ ឬនៅមិនទាន់លាយពណ៌ ឬក្នុងទម្រង់ដុំតូចៗ |
| | | - ស៊ីម៉ងត៍ផតឡែន |
| | 2523.21.00 | - - ស៊ីម៉ងត៍ស ទោះបីមានពណ៌ ឬមិនមានពណ៌តាមបែបសិប្បនិម្មិតក៏ដោយ |
| | 2523.29.10 | - - - ស៊ីម៉ងត៍ពណ៌ |
| | 2523.29.90 | - - - ផ្សេងទៀត |
| ២ | **70.05** | កញ្ចក់កែវអណ្តែតនិងផ្ទៃខាត់រលោង ឬកញ្ចក់រំលីង ជាសន្លឹក ទោះជាមានឬមិនមានស្រទាប់ស្រូប ចាំង ឬមិនមានស្រទាប់ចាំង ប៉ុន្តែបើមិនដូច្នោះ បានកែច្នៃ។ |
| | 7005.29.90 | - - - ផ្សេងទៀត |
| | 7005.30.00 | - កញ្ចក់មានសរសៃ |
| ៣ | **70. 06** | កញ្ចក់មានក្បាលកោង៧០.០៣, ៧០.០៤ ឬ ៧០.០៥ កែច្នៃគែម ឆ្លាក់ ខួង លាបពណ៌ ឬកែច្នៃផ្សេងទៀត ប៉ុន្តែមិនមានដាក់ស៊ុម ឬដាក់ភ្ជាប់ដោយវត្ថុផ្សេងទៀត |
| | 7006.00.90 | - ផ្សេងទៀត |
| ៤ | **70.07** | កញ្ចក់សុវត្ថិភាព រួមមានកញ្ចក់ស្វិត(លុត) ឬកញ្ចក់អ៊ិត |
| | | - កញ្ចក់ស្វិតសុវត្ថិភាព(លុត) |
| | 7007.19.90 | - - - ផ្សេងទៀត |
| ៥ | **70.08**<br>**7008.00.00** | កញ្ចក់ភ្ជាប់ដោយគ្រឿងអ៊ីសូឡង់ច្រើនស្រទាប់<br>Multiple-walled insulating units of glass |
| ៦ | **70. 09** | កញ្ចក់ឆ្លុះ ទោះមាន ឬគ្មានស៊ុម រាប់បញ្ចូលទាំងកញ្ចក់មើលក្រោយ |
| | 700[illegible].91.0[illegible] | - ផ្សេងទៀត៖<br>- - គ្មានស៊ុម |
| | [illegible].92.00 | - - មានស៊ុម |
| ៧ | 72[illegible] | ដែកឬមិនមែនដែក ក្នុងទម្រង់ជារបារនិងសរសៃ ឬដែកហូតក្តៅជារបុំរមូរ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| | 7213.10.10 | ដែលមានថ្នាំង ទ្រនុង ឬស្នាមផ្សេងៗទៀតបង្កើតឡើងកំឡុងពេលដំណើរការកិនៈ- - នៃមុខកាត់មូលមានរង្វាស់អង្កត់ផ្ចិតមិនលើសពី ៥០ម.ម. |
| | 7213.10.90 | - - ផ្សេងទៀត |

២- បញ្ជីសម្ភារៈអគារនិងសំណង់ ត្រូវបានត្រួតពិនិត្យឡើងវិញជាប្រចាំដោយJSC ដែលរក្សាសិទ្ធិក្នុងការកែប្រែបញ្ជីនេះផ្អែកលើការព្រមព្រៀងរបស់បណ្ដារដ្ឋសមាជិក។

## ឧបសម្ព័ន្ធខ

## នីតិវិធីនិងការតម្រូវទាក់ទិននឹងការចុះបញ្ជី ការព្យួរ ការលុបចោល ការផ្ទៀងផ្ទាត់ និងសមត្ថភាពបច្ចេកទេសរបស់អង្គភាពវាយតម្លៃភាពអនុលោម (CABs)

## ជំពូកក

## ការចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម

១- អង្គភាពចាត់តាំងមួយត្រូវធ្វើអត្តសញ្ញាណកម្មនិងតែងតាំងCABs សម្រាប់ការចុះបញ្ជីស្របតាមជំពូកងនិងនីតិវិធីដូចមានចែងក្នុងឧបសម្ព័ន្ធនេះ។

២- CABs ដែលត្រូវបានកំពុងស្វែងរកការចុះបញ្ជីនៅក្រោមMRAតាមផ្នែកនេះ ត្រូវដាក់ជូននូវភស្តុតាងជាឯកសារទៅអង្គភាពចាត់តាំង ដើម្បីបញ្ជាក់ថាអង្គភាពទាំងនោះបានបំពេញនូវការតម្រូវសមត្ថភាពបច្ចេកទេសដូចមានចែងក្នុងជំពូកង។

៣- អង្គភាពចាត់តាំងត្រូវពិនិត្យឡើងវិញនូវឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ និងត្រូវដាក់ជូននូវសេចក្ដីលម្អិតជាលាយលក្ខណ៍អក្សរអំពីCAB ដែលបានស្នើ ដើម្បីចុះបញ្ជីក្រោមMRAតាមផ្នែកនេះ ទៅJSC តាមរយៈលេខាធិការដ្ឋានអាស៊ាន ដើម្បីធ្វើការពិចារណាស្របតាមនីតិវិធី ដូចខាងក្រោមៈ

ក- ក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីការទទួលបាននូវឯកសារដែលបានដាក់ជូនដោយអង្គភាពចាត់តាំងទៅសមាជិកJSC របស់ខ្លួនៈ

(១)- សមាជិកJSC ត្រូវតែដាក់ជូននូវបញ្ជីCAB ដែលបានស្នើសុំចុះបញ្ជីក្រោមMRAតាមផ្នែកនេះទៅJSC តាមរយៈលេខាធិការដ្ឋានអាស៊ាន។

(២)- សមាជិកJSC ត្រូវបង្ហាញពីជំហររបស់ខ្លួនចំពោះការអនុម័តទទួលយកឬការបដិសេធក្នុងការបញ្ចូល CAB ដែលបានស្នើសុំចុះបញ្ជីក្នុងឧបសម្ព័ន្ធគ។

(៣)- ប្រសិនបើមិនទទួលបានការឆ្លើយតបពីសមាជិកJSCណាមួយ សមាជិកJSCអវត្តមានមួយនោះត្រូវបានចាត់ទុកថាមិនមានការជំទាស់ក្នុងការបញ្ចូលCAB ដែលបានស្នើសុំចុះបញ្ជីក្នុងឧបសម្ព័ន្ធគ នោះឡើយ។

ប្រសិនបើទទួលបានការអនុម័តទទួលយកពីJSC នៅថ្ងៃចុងក្រោយនៃរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិន CABនោះ ត្រូវតែបានដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធគ។

(៤)- CABនោះ ត្រូវបានប្រកាសជូនដំណឹងអំពីការដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធគ ដោយលេខាធិការដ្ឋានអាស៊ាន។

ខ- នៅក្រោយពេលមានការស្នើសុំដោយមានហេតុផលត្រឹមត្រូវពីបណ្ដារដ្ឋសមាជិកមួយឬច្រើន សម្រាប់ការផ្ទៀងផ្ទាត់នូវសមត្ថភាពបច្ចេកទេសរបស់CABដែលបានស្នើនោះ JSCអាចធ្វើការសម្រេចចិត្តថា សមត្ថភាពបច្ចេកទេសរបស់ CABដែលបានស្នើសុំនឹងត្រូវបានផ្ទៀងផ្ទាត់ស្របតាមជំពូកង។ ការស្នើសុំដោយរដ្ឋសមាជិកសម្រាប់ការផ្ទៀងផ្ទាត់បែបនេះ ត្រូវបានដាក់ជូនទៅJSC តាមរយៈលេខាធិការដ្ឋានអាស៊ាន និង

គ- CABដែលបានស្នើសុំនោះ មិនត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធគឡើយ រហូតដល់មានការសម្រេចត្រូវបានធ្វើឡើងក្នុងការបញ្ចូលCABនោះ។

៤- លេខាធិការដ្ឋានអាស៊ានត្រូវរក្សាឧបសម្ព័ន្ធគ ក្រោមMRAតាមផ្នែកនេះ។

## ជំពូកខ
## ការព្យួរអង្គភាពវាយតម្លៃភាពអនុលោមដែលបានចុះបញ្ជី

នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះការព្យួរCAB ដែលបានចុះបញ្ជី ក្នុងMRAតាមផ្នែកនេះ៖

ក- រដ្ឋសមាជិកណាមួយដែលជំទាស់តវ៉ាលើសមត្ថភាពបច្ចេកទេសឬអនុលោមភាពរបស់CABមួយដែលបានចុះបញ្ជីត្រូវដាក់ជូននូវសេចក្ដីប្រកាសជូនដំណឹងមួយតាមរយៈចំណុចទំនាក់ទំនងរបស់ខ្លួន ទៅJSCតាមរយៈលេខាធិការដ្ឋានអាស៊ានដោយភ្ជាប់ជាមួយនូវការបញ្ជាក់អះអាងពាក់ព័ន្ធជាលាយលក្ខណ៍អក្សរ។

ខ- លេខាធិការដ្ឋានអាស៊ានត្រូវប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ ទៅCAB ដែលពាក់ព័ន្ធនោះ។ CAB នោះត្រូវបានផ្ដល់ជូនរយៈពេល៣០ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីការទទួលបាននូវការប្រកាសជូនដំណឹងពីលេខាធិការដ្ឋានអាស៊ាន ដែលរយៈពេលនេះអាចនឹងត្រូវពន្យារដោយJSC នៅពេលមានការស្នើសុំដោយមានហេតុផលសមស្របពីCAB នោះ ដើម្បីបង្ហាញព័ត៌មានឆ្លើយតបទៅនឹងការបញ្ជាក់អះអាងនៅក្នុងកថាខណ្ឌក ឬដើម្បីកែតម្រូវចំណុចខ្វះចន្លោះដែលបង្កើតជាមូលដ្ឋាននៃការជំទាស់តវ៉ានោះ។

គ- ការជំទាស់តវ៉ាណាមួយបែបនេះត្រូវបានពិភាក្សាដោយJSC ដែលអាចធ្វើការពិចារណាសម្រេចព្យួរCAB នោះ។ ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយដោយJSC ក្នុងរយៈពេល២១ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានការឆ្លើយតបពីCAB នោះ ហើយក្នុងរយៈពេលពន្យារនៃការដោះស្រាយដោយJSC CABនោះត្រូវបានព្យួរអាស្រ័យទៅតាមការតវ៉ារបស់រដ្ឋសមាជិក។ លេខាធិការដ្ឋានអាស៊ានត្រូវជូនដំណឹងដល់CAB នោះ អំពីសេចក្ដីសម្រេចដែលបានធ្វើឡើងដោយJSC។ ក្នុងកំឡុងពេលរង់ចាំការសម្រេចរបស់JSC អាជ្ញាធរបញ្ញត្តកម្មនៃរដ្ឋសមាជិកដែលរងការជំទាស់តវ៉ានោះ អាចចាត់គ្រប់វិធានការសមស្រប ដោយអនុលោមតាមប្រការដែលមានចែងក្នុងមាត្រា៨។

ឃ- នៅពេលដែលJSC សម្រេចថា ការផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេស ឬអនុលោមភាពត្រូវបានតម្រូវឱ្យអនុវត្តការផ្ទៀងផ្ទាត់បែបនេះ ត្រូវបានធ្វើឡើងស្របតាមជំពូកឃ។

ង- នៅក្រោយពេលផ្អាកCAB ដែលបានចុះបញ្ជីមួយនៅក្រោមMRA តាមផ្នែកនេះ បណ្ដារដ្ឋសមាជិក ឈប់មានលទ្ធភាពទទួលយករបាយការណ៍តេស្តឬវិញ្ញាបនបត្រ ដែលបានចេញដោយCABនោះ ជាបន្តទៀត។ [illegible]តាមមាត្រា៨ បណ្ដារដ្ឋសមាជិកត្រូវបន្តទទួលយករបាយការណ៍តេស្តឬវិញ្ញាបនបត្រ ដែលបានចេញដោយCAB នោះមុនពេលដែលត្រូវបានព្យួរ និង

ច- ការព្យួរនេះត្រូវតែនៅមានប្រសិទ្ធភាពរហូតដល់មានកិច្ចព្រមព្រៀងមួយបានឯកភាពដោយJSC ស្ដីពីស្ថានភាពនាពេលអនាគតរបស់CABនោះ។

## ជំពូកគ
## ការលុបចោលអង្គភាពវាយតម្លៃភាពអនុលោមដែលបានចុះបញ្ជី

នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះការលុបចោលCAB ដែលបានចុះបញ្ជី ក្នុងMRAតាមផ្នែកនេះ៖

ក- រដ្ឋសមាជិកមួយស្នើសុំលុបចោលនូវCAB ដែលបានចុះបញ្ជីមួយនៅក្នុងMRAតាមផ្នែកនេះ ត្រូវដាក់ជូនតាមរយៈចំណុចទំនាក់ទំនងរបស់ខ្លួននូវសំណើរដោយមានបញ្ជាក់ពីគោលបំណងនិងហេតុផលត្រឹមត្រូវជាលាយលក្ខណ៍អក្សរទៅJSC តាមរយៈលេខាធិការដ្ឋានអាស៊ាន។

ខ- CABនេះ ត្រូវបានប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដោយលេខាធិការដ្ឋានអាស៊ាន ហើយត្រូវបានផ្តល់ជូននូវរយៈពេល៣០ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃទទួលបាននូវការប្រកាសជូនដំណឹង ដែលរយៈពេលនេះអាចនឹងត្រូវពន្យារបានដោយJSC ដើម្បីបង្ហាញព័ត៌មានអំពីការបដិសេធឬការកែតម្រូវភាពខ្វះចន្លោះ ដែលបង្កើតជាមូលដ្ឋាននៃការស្នើសុំលុបចោលនោះ។

គ- ក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីទទួលបាននូវសំណើ៖

(១)- JSC ត្រូវបង្ហាញពីជំហររបស់ខ្លួនចំពោះការអនុម័តឬការបដិសេធរបស់ខ្លួនក្នុងការលុបចោលនូវCAB ដែលបានស្នើដកចេញពីឧបសម្ព័ន្ធគ។

(២)- ប្រសិនបើមិនមានការឆ្លើយតបពីសមាជិកJSCមួយ ភាពអនុបវាទរបស់សមាជិកJSC នោះនឹងត្រូវចាត់ទុកថាមិនមានការជំទាស់ក្នុងការលុបចោលCAB ដែលបានស្នើដកចេញពីឧបសម្ព័ន្ធគ។

(៣)- នៅចុងបញ្ចប់នៃរយៈពេល៦០ថ្ងៃនៃថ្ងៃប្រតិទិន CABនោះ ត្រូវបានលុបចេញពីឧបសម្ព័ន្ធគ អាស្រ័យលើការអនុម័តយល់ព្រមពីJSC និង

(៤)- CABនោះ ត្រូវបានប្រកាសជូនដំណឹងអំពីការលុបចោលចេញពីឧបសម្ព័ន្ធគ ដោយលេខាធិការដ្ឋានអាស៊ាន។

ឃ- ប្រសិនបើJSC រកឃើញមូលដ្ឋានគ្រប់គ្រាន់ដោយផ្អែកលើភស្តុតាងដែលបានដាក់ស្នើ JSCអាចសម្រេចឱ្យធ្វើការផ្ទៀងផ្ទាត់រួមគ្នាមួយរបស់ស្ថាប័នពាក់ព័ន្ធ។ ក្នុងរយៈពេលរង់ចាំការបញ្ចប់នូវការផ្ទៀងផ្ទាត់រួមគ្នាCAB នោះមិនត្រូវបានលុបចេញពីបញ្ជីCABរៀងខ្លួននីមួយៗដែលបានទទួលយកដោយឡើយ និង

ង- មុនពេលនៃការលុបចោលនូវCABមួយដែលបានចុះបញ្ជីនៅក្នុងMRAតាមផ្នែកនេះ ហើយផ្អែកតាមមាត្រា៨ បណ្តារដ្ឋសមាជិកត្រូវបន្តទទួលយករបាយការណ៍តេស្តឬវិញ្ញាបនបត្រដែលចេញដោយCABនោះ។

## ជំពូកឃ
## ការផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេសនិងអនុលោមភាពរបស់អង្គភាពវាយតម្លៃភាពអនុលោម

១- អង្គភាពភាគីនានាត្រូវធានាថា CABដែលបានកំណត់អត្តសញ្ញាណ ត្រូវតែមានវត្តមានសម្រាប់ការផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេស និងអនុលោមភាពរបស់វាជាមួយនឹងការតម្រូវដែលអាចអនុវត្តបាននៅពេលដែលJSCត្រូវការ។

២- សំណើជាលាយលក្ខណ៍អក្សរ ត្រូវតែបានដាក់ជូនលេខាធិការដ្ឋានអាស៊ានសម្រាប់ការស្នើសុំណាមួយដើម្បីផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេសឬអនុលោមភាពរបស់CABនោះ ដែលសេចក្តីបញ្ជាក់អះអាងនោះត្រូវតែបានបញ្ជូនជាបន្ទាន់ទៅJSC ដើម្បីធ្វើការសម្រេច។

៣- នៅពេលដែលJSC សម្រេចថា ការផ្ទៀងផ្ទាត់សមត្ថភាពបច្ចេកទេសឬអនុលោមភាព ត្រូវបានតម្រូវឱ្យអនុវត្តការផ្ទៀងផ្ទាត់នោះត្រូវបានធ្វើក្នុងរបៀបមួយទាន់ពេលវេលា ដោយផ្អែកតាមនីតិវិធីនិងលក្ខណវិនិច្ឆ័យដែលមានចែងក្នុងជំពូកង។

៤- លទ្ធផលនៃការផ្ទៀងផ្ទាត់នេះត្រូវតែបានពិភាក្សាដោយJSC ដោយឈរលើគោលជំហរដោះស្រាយបញ្ហាណាមួយដែលកើតមានឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ជំពូកខ
## សមត្ថភាពបច្ចេកទេសរបស់អង្គភាពវាយតម្លៃភាពអនុលោម

១- តម្រូវការទូទៅសម្រាប់ការបកស្រាយពីសមត្ថភាពបច្ចេកទេសរបស់CAB ត្រូវតែផ្អែកលើៈ

ក- ចំណេះដឹងបច្ចេកទេសអំពីផលិតផលនិងដំណើរការពាក់ព័ន្ធ។

ខ- ការយល់ដឹងអំពីស្តង់ដាបច្ចេកទេសនិងសុខភាព សុវត្ថិភាព ហើយនិងការតម្រូវបរិស្ថាន សម្រាប់អ្វីដែលការចាត់តាំងនោះ ត្រូវបានរកឃើញ។

គ- បទពិសោធពាក់ព័ន្ធទៅនឹងនីតិប្បញ្ញត្តិ បញ្ញត្តកម្ម និងបទប្បញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន។

ឃ- សមត្ថភាពពិតប្រាកដដើម្បីអនុវត្ត ក្នុងការធ្វើតេស្តពាក់ព័ន្ធ និង

ង- ក្នុងកាលៈទេសៈចាំបាច់ណាមួយដើម្បីផ្តល់ការធានាថា ការធ្វើតេស្តនោះ នឹងត្រូវបានធ្វើគ្រប់គ្រាន់ និងបានគ្រប់គ្រងដោយសង្គតិភាពជាមូលដ្ឋាន។

២- CABs ដែលកំពុងស្វែងរកការចុះបញ្ជីនៅក្រោមMRAតាមផ្នែកនេះ ត្រូវបំពេញនូវការតម្រូវអំពីសមត្ថភាពបច្ចេកទេសដូចខាងក្រោមៈ

ក- ទទួលបាន វិញ្ញាបនបត្រ មួយក្នុងចំណោមៈ

(១)- វិញ្ញាបនបត្រនៃការវាយតម្លៃទទួលស្គាល់តាមស្តង់ដាអន្តរជាតិISO/IEC 17025 - តម្រូវការទូទៅសម្រាប់សមត្ថភាពមន្ទីរពិសោធន៍ធ្វើតេស្ត និងមន្ទីរពិសោធន៍ព្យាសកម្ម សម្រាប់មន្ទីរពិសោធន៍ធ្វើតេស្ត ឬ

(២)- វិញ្ញាបនបត្រនៃការវាយតម្លៃទទួលស្គាល់តាមស្តង់ដាអន្តរជាតិISO/IEC 17065 - ការតម្រូវសម្រាប់អង្គភាព អង្គភាពផ្តល់វិញ្ញាបនបត្របញ្ជាក់ផលិតផល ដំណើរការ និងសេវាកម្មសម្រាប់ការផ្តល់វិញ្ញាបនបត្រផលិតផល។

ខ- បានវាយតម្លៃទទួលស្គាល់ដោយអង្គភាពវាយតម្លៃទទួលស្គាល់ ដែលជាហត្ថលេខីមួយនៃកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមករបស់សហប្រតិបត្តិការវាយតម្លៃទទួលស្គាល់អាស៊ីប៉ាស៊ីហ្វិក(APAC)។

គ- វិសាលភាពនៃការវាយតម្លៃទទួលស្គាល់របស់CABs។

**ឧបសម្ព័ន្ធគ**
**អង្គភាពវាយតម្លៃភាពអនុលោមដែលបានចុះបញ្ជី**

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ASSOCIATION
OF SOUTHEAST
ASIAN NATIONS

The ASEAN Secretariat
70 A Jl. Sisingamangaraja
Jakarta 12110
Indonesia

Phone: (62-21) 726 2991
(62-21) 724 3372
Fax: (62-21) 739 8234
(62-21) 724 3504

asean@secretariat.org
www.asean.org

## CERTIFYING STATEMENT

**ASEAN Sectoral Mutual Recognition Arrangement for Building and Construction Materials; Instrument of Extension of the ASEAN Petroleum Security Agreement; and Instrument of Extension of the Memorandum of Understanding on the ASEAN Power Grid**

I, THE UNDERSIGNED Deputy Secretary-General of ASEAN for Community and Corporate Affairs, hereby certify that the attached texts are **true and complete copies** of:

1. ASEAN Sectoral Mutual Recognition Arrangement for Building and Construction Materials, signed on 9 March 2024 in Phnom Penh, Cambodia;

2. Instrument of Extension of the ASEAN Petroleum Security Agreement, signed on 22 March 2023 in Bandar Seri Begawan, Brunei Darussalam; Phnom Penh, Cambodia; Jakarta, Indonesia; Vientiane, Lao PDR; Kuala Lumpur, Malaysia; Nay Pyi Taw, Myanmar; Manila, Philippines; Singapore; Bangkok, Thailand; Ha Noi, Viet Nam; and

3. Instrument of Extension of the Memorandum of Understanding on the ASEAN Power Grid, signed on 18 March 2024 in Bangkok, Thailand.

Jakarta, 3 June 2024

**Nararya S. Soeprapto**
Deputy Secretary-General of ASEAN
Community and Corporate Affairs

one vision
one identity
one community

asean

# ASEAN SECTORAL MUTUAL RECOGNITION ARRANGEMENT FOR BUILDING AND CONSTRUCTION MATERIALS

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Member States" or individually as "Member State");

**ASPIRING** to achieve economic integration and turning the diversity that characterises the region into opportunities for business complementation making ASEAN a more dynamic and stronger segment of the global supply chain and the world economy as envisaged in the ASEAN Charter, the Declaration on the ASEAN Economic Community Blueprint signed on 20 November 2007 in Singapore, and the ASEAN Economic Community Blueprint 2025 adopted on 22 November 2015 in Kuala Lumpur, Malaysia;

**DETERMINED** to realise the goals of establishing ASEAN as a single market and production base which is stable, prosperous, highly competitive, and economically integrated with effective facilitation for trade and investment in which there are free flow of goods, services and investments, facilitation for movement of business persons, professionals, talents and labour, and freer flow of capital as the end-goal of ASEAN;

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

**RECALLING** the ASEAN Trade in Goods Agreement (ATIGA) signed on 26 February 2009 in Cha-am, Thailand and the ASEAN Framework Agreement on Mutual Recognition Arrangements signed on 16 December 1998 in Hanoi, Viet Nam to facilitate the elimination of technical barriers to trade and to enhance trade in ASEAN;

**RECOGNISING** that mutual recognition of results of conformity assessment procedures is an important means of reducing technical barriers to trade and that such mutual recognition is of particular interest to businesses in ASEAN;

**MINDFUL** of the different levels of infrastructure for technical regulations, standards, certifications, inspections and analyses, and the different levels of economic development of Member States;

**REITERATING** that Member States' commitments under the World Trade Organization (WTO) Agreement on Technical Barriers to Trade are reaffirmed in ATIGA and noting that WTO Members are encouraged to enter into negotiations for the conclusion of agreements for the mutual recognition of results of each other's conformity assessment procedures which include, *inter alia,* procedures for sampling, testing and inspection, evaluation, verification and assurance of conformity, registration, accreditation and approval, as well as their combinations;

**DESIRING** to establish a Sectoral Mutual Recognition Arrangement for conformity assessment results for building and construction materials to facilitate the movement of building and construction materials in ASEAN,

**HAVE AGREED AS FOLLOWS:**



CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

## ARTICLE 1
## DEFINITIONS

For purposes of this ASEAN Sectoral Mutual Recognition Arrangement for Building and Construction Materials (hereinafter referred to as "Sectoral MRA"), the following definitions shall apply:

(a) **accept** means the use of test reports or certifications as a basis for regulatory actions such as approvals, licenses, and post-market assessments of conformity;

(b) **accreditation** means a statement issued by an independent body conveying confirmation of a conformity assessment body's competence to carry out specific conformity assessment tasks;

(c) **accreditation body** means an authoritative body that performs accreditation;

(d) **building and construction materials** means any type, size, and nature of material, whether initial, temporary, intermediate, or finished, which is used for construction purposes;

(e) **certification** means a procedure by which a third party gives written or other assurance that a product, process, or service conforms to specified requirements;

(f) **conformity assessment** means demonstration that specified requirements relating to a product, process, system, person, or body are fulfilled;



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

(g) **Conformity Assessment Body** (hereinafter referred to as "CAB") means a body that performs conformity assessment services which fulfil the requirements of technical competence set out in Section A and Section E of Annex B;

(h) **conformity assessment procedure** means any procedure used, directly or indirectly, to determine that relevant requirements in technical regulations or standards are fulfilled;

(i) **contact point** means a person, position, or body with and through whom Member States will exchange information and communicate in accordance with the requirements of this Sectoral MRA;

(j) **Designating Body** means a body established within government or empowered by government to designate CAB, suspend or withdraw their designation, or remove their suspension from designation;

(k) **designation** means governmental authorisation of a CAB to perform specified conformity assessment activities;

(l) **Listed CAB** means a locally owned or foreign CAB located in the territory of a Member State duly listed in accordance with the requirements of this Sectoral MRA;

(m) **recognition of conformity assessment results** means acknowledgement of the validity of a conformity assessment result provided by another person or body;



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

(n) **Regulatory Authority** means an entity that has been granted a legal right to control the import, use, or sale of products within a Member State's jurisdiction which may take enforcement action to ensure that products marketed within its jurisdiction comply with legal requirements; and

(o) **standard** means a document approved by a recognised body, that provides, for common and repeated use, rules, guidelines or characteristics for products, or related processes and production methods, with which compliance is not mandatory. It may also include or deal exclusively with terminology, symbols, packaging, marking or labelling requirements as they apply to a product, process or production method.

## ARTICLE 2
## OBJECTIVES

The objective of this Sectoral MRA is to enable the mutual recognition of test reports or certification of building and construction materials issued by the Listed CABs.

## ARTICLE 3
## SCOPE

1. The scope of this Sectoral MRA is to facilitate mutual recognition of conformity assessment results of building and construction materials, as listed in Annex A on List of Building and Construction Materials within the Scope of this Sectoral MRA (hereinafter referred to as "Annex A").



CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. This Sectoral MRA applies to all instances where test reports or certifications are used as the basis for regulatory action in respect of building and construction materials.

## ARTICLE 4
## GENERAL PROVISIONS

1. Member States shall accept the test reports or certifications which have been issued by the Listed CABs.

2. Where test reports or certifications have been issued in respect of Member States' products specifications of building and construction materials that have been imported, importing Member States retain the right to verify the conformity assessment results of building and construction materials.

3. In the absence of harmonised standards, a Member State seeking to export building and construction materials to an importing Member State shall comply with that importing Member State's standards.

4. Member States shall strengthen and enhance existing cooperation efforts in information exchange, through their contact points, concerning their regulatory requirements, conformity assessment procedures and regimes, and through confidence building, *inter alia*:

   (a) establishment or improvement of technical infrastructure in calibration, testing, certification, and accreditation to meet relevant international requirements for building and construction materials;

   (b) cooperation and participation in proficiency testing for building and construction materials; or



CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

(c) active participation in relevant arrangements undertaken by specialist regional and international bodies.

| ៧- ឧបាសិកា | ស៊ឹម សូលី | ៨- លោក | ផាយ សុំម៉ាក់ |
| ៩- លោកស្រី | សំរិទ្ធ ចាន់ធី | ១០- លោកស្រី | មឿ ម៉ាល័យ |
| ១១- លោក | អៀម អឿន | ១២- លោក | ស្រេង ម៉េងទាង |

ញ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- ព្រះប្រយោសាភិវ័ឌ្ឍវង្សី | ប៊ឹត បាន | ២- ភិក្ខុសិរីវឌ្ឍនោ | រេន សុភា |
| ៣- លោក | សាន វិរៈបុត្រ | ៤- វរសេនីយ៍ទោ | ណាំ បូរី |

| | | | |
|---|---|---|---|
| ៥- វរសេនីយ៍ត្រី | តឹក សុផល | ៦- អនុសេនីយ៍ឯក | សាំង ស៊ីថាន |
| ៧- អនុសេនីយ៍ឯក | គង់ ហាង៉ង | ៨- អនុសេនីយ៍ត្រី | ច័ន្ទ ឧត្តមដារ៉ា |
| ៩- លោក | គង់ ច័ន្ទដារ៉ា | ១០- លោក | នាង ចាន់វណ្ណៈ |
| ១១- វរសេនីយ៍ទោ | ព្រឿង ផាន់ណាក់ | ១២- វរនាវីទោ | ហ៊ឹម សំណាង |
| ១៣- វរសេនីយ៍ត្រី | ឆេក ដារាវិចិត្រ | ១៤- អនុសេនីយ៍ឯក | វុធ ប៊ុនស៊ូង |
| ១៥- លោក | ធូរ មិនា | ១៦- អនុសេនីយ៍ឯក | ហ៊ន់ លីហ៊ាង |
| ១៧- លោកស្រី | អ៊ុយ ឡៃហៀង | ១៨- លោក | ផៃ ចេងឡុង |

ជ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | | |
|---|---|---|---|
| ១- វរសេនីយ៍ទោ | ញ៉ាត ស៊ីថុល | ២- អនុសេនីយ៍ទោ | ឡុង គា |

ឋ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១- អនុសេនីយ៍ឯក | ម្លូរ ឧត្តមបញ្ញា | ២- លោក | ហេង សោមពិសិដ្ឋ |

បរមលេខា

នរោត្តម សីហមុនី

រាជ.ក.២៦០៥.៧៦៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៨៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល



។

## សម្រេច

**មាត្រាមួយ .-**

មាត្រា១នៃអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (**គ.ស.អ**) ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា១ .- ថ្មី**

ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហៅកាត់ថា **គ.ស.អ** ដើម្បីបញ្ជាដឹកនាំកិច្ចការការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គ្រប់នីតិកាល ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ប្រធានអង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មួយចំនួន | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិកអចិន្ត្រៃយ៍ |
| - អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃក្រសួងមហាផ្ទៃ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| - មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| - មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត សមាជិក។

**គ.ស.អ** អាចមានសមាសភាពបន្ថែមជាអនុប្រធាននិងសមាជិក តាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពជាក់ស្ដែងរបស់ **គ.ស.អ** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៩៩ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីប្រតិបត្តិ នៃសាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាប ចំនួន ៨រូប ដែលមានគុណបំណាច់ និងស្នាដៃបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងពេលវេលា បម្រើការងារក្នុងសកម្មភាពមនុស្សធម៌កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

លោក ស៊ត់ ឡៃ។

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- លោកស្រី នូ វណ្ណៈ

២- លោក លិវ ឡុន

៣- លោកស្រី កែវ គឹមអាន។

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោក ជឿន វិចិត្រ

២- លោក ម៉ៅ វុទ្ធា

៣- លោក ឌួង ប៊ុនធី

៤- លោកស្រី សំ សារ៉ាង។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានកាកបាទក្រហមកម្ពុជា និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៥ រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ៥រូប ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- វរសេនីយ៍ទោ ទី សុខេន អត្តលេខ ៧១១៧៧
២- វរសេនីយ៍ត្រី ហាំង លាភសុវណ្ណនា អត្តលេខ ៧៨៦៨៦
៣- ព្រឹន្ទបាលឯក សឿង ចាន់ណាការ៉ា អត្តលេខ ៩២៨៨០។

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- លោក យង់ វិសាល

២- លោកស្រី ផល ស្រីដែត។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៥ រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០១ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ពាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ .–**

ត្រូវបានបំពាក់មេដាយ **មាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន ៣៤អង្គ/រូប ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

១- ព្រះគ្រូកន្តសីលោ ណាំ ម៉ែ
២- ព្រះតេជគុណ ហុង ហឿន
៣- ព្រះតេជគុណ ឃឹម វណ្ណា
៤- ព្រះតេជគុណ កែវ កូ
៥- ព្រះតេជគុណ កង សិលា
៦- លោកអាចារ្យ ស្រស់ បាន
៧- លោកអាចារ្យ ប្រាក់ ពៅ
៨- លោកអាចារ្យ បេប រ៉េ
៩- ឧបាសក ជា សឿន
១០- ឧបាសិកា ស៊ីវ កត់

១១- ឧបាសក កែ សូ
១២- ឧបាសក ស៊ិន លន
១៣- ឧបាសក អ៊ូ ម៉ៅ
១៤- ឧបាសក អ៊ុង ប៊ុនថន
១៥- ឧបាសក ស៊ែ មឿន
១៦- ឧបាសក ឡឹង ចាន់
១៧- ឧបាសក មាស អ៊ី
១៨- ឧបាសិកា មាស វ៉េត
១៩- ឧបាសិកា សុខ ជា
២០- ឧបាសិកា ចែម ម៉ៅ
២១- ឧបាសិកា ខៀវ យ៉ាន
២២- ឧបាសក អ៊ឹម ធីយ
២៣- ឧបាសក គយ កាន់
២៤- ឧបាសិកា អ៊ិន សុផាត
២៥- ឧបាសិកា រី យឺន
២៦- លោក យ៉យ ខាន់
២៧- ឧបាសក យោ ភិរុន
២៨- ឧបាសក មាស សារុន
២៩- ឧបាសក សួន វឿន
៣០- ឧបាសក ហាំង ប៊ុនហឿន
៣១- ឧបាសិកា សឿន រូ
៣២- លោកស្រី ឈុំ កន្និថា
៣៣- លោក ប្រាក់ ប៊ុនធឿន
៣៤- លោក ឆាយ រ៉ែន។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៥រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០២ អនក្រ.តត

## អនុក្រឹត្យ

## ស្ដីពី

## ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .—**

ត្រូវបានផ្ទេរភារកិច្ចលោក **ជួ បុត្រ** ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ២ ពីអភិបាលនៃគណៈអភិបាលស្រុកភ្នំស្រុក ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តបន្ទាយមានជ័យ។

**មាត្រា២ .—**

ត្រូវបានតែងតាំងលោកស្រី **ចំរើន ដាណេ** ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**មាត្រា៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦០៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែងទីប្រឹក្សា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១០៩២ អនក្រ.តត ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបញ្ចប់មុខតំណែងលោកស្រី **ប៉ុក ចន្ទ្រីមករាកត** ពីទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អគ្គនាយករង។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦០៤ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្មើនាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ទឹម មុនីរតន្ន៍** អត្តលេខ **១៦៧១២០០៤១៧** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ឱ្យបំពេញមុខងារជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសលោក **លឹម ចាន់សុភី** ដែលបានចូលនិវត្តន៍។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងទីប្រឹក្សា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការក្នុងអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានតែងតាំងលោក **ភើត សារឿន** ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើអគ្គនាយករង។

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០៦ អនក្រ.តត

# អនុក្រឹត្យ

# ស្តីពី

# ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្នើនាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



ៗ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **អ៊ិន មុន្នីទ្រី** អត្តលេខ **១៧២១០០០០៩៩** ឋាននន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ **៥** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ឱ្យបំពេញមុខងារជាប្រធានមន្ទីរអធិការកិច្ចខេត្តក្រចេះ នៃក្រសួងអធិការកិច្ច ជំនួសលោក **ញិប វិចិត្រ** ដែលបានចូលនិវត្តន៍។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០៧..អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ ស្តីពីការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ



ϕ

- បានឃើញអនុក្រឹត្យលេខ៦៩៦ អនក្រ.តត ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .—**

ត្រូវបានតែងតាំង ឯកឧត្តម **ជាញ់ សេរី** អគ្គនាយក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន ជាសមាជិកក្រុមប្រឹក្សាភិបាល នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ ជំនួស ឯកឧត្តម **ប៉ាត សុខារ៉ាឌុត**។

**មាត្រា២ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**៦០៨.អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការផ្ទេរយោធិនពលី មរណៈ
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.-**

ត្រូវបានផ្ទេរយោធិនពលី មរណៈ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | គន្ធ តារាវណ្ណ | អត្តលេខ០០១៣១៥ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ឯក | មាស ស៊ុំ | អត្តលេខ០០៤៩៧៦ មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការសម្តេចតេជោ ហ៊ុន សែន ៣១៧គូលេនសៀមរាប |

| | | | |
|---|---|---|---|
| ៣-ឧត្តមសេនីយ៍ឯក | សុខ ឫទ្ធី | អត្តលេខ២០៣៩៥៤៨ | អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស |
| ៤-ឧត្តមសេនីយ៍ឯក | គុំ ចាន់ថុល | អត្តលេខ២០០៨៤២៤ | អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស |
| ៥-ឧត្តមសេនីយ៍ត្រី | ទូច និលរ័ត្ន | អត្តលេខ១០២១៣៥ | អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ |
| ៦-ឧត្តមសេនីយ៍ត្រី | តាំង ធី | អត្តលេខ២០៣៩៦៣០ | អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ |
| ៧-ឧត្តមសេនីយ៍ត្រី | វង្ស ស៊ីនួន | អត្តលេខ២០០២០៧២ | អគ្គនាយកដ្ឋានយោធសេវា |
| ៨-ឧត្តមសេនីយ៍ត្រី | គង់ ប៊ុនថាន | អត្តលេខ២០៤៧២៤៥ | នាយកដ្ឋានព័ត៌មាន |
| ៩-ឧត្តមសេនីយ៍ត្រី | អ៊ុក ដារិទ្ធ | អត្តលេខ២០២៤៩១៦ | មជ្ឈមណ្ឌលបំប៉នសុខភាពយោធិនពិការ៣១៧កោះស្លា |
| ១០-ឧត្តមសេនីយ៍ត្រី | ព្រំ ប៊ិន | អត្តលេខ១៥៨៧៩៤ | អគ្គនាយកដ្ឋានយោធសេវា |
| ១១-ឧត្តមសេនីយ៍ត្រី | យ៉េង ស៊ីនិត | អត្តលេខ២៣៤៣១២ | អគ្គនាយកដ្ឋានយោធសេវា |
| ១២-ឧត្តមសេនីយ៍ត្រី | ពិល ផន | អត្តលេខ២០១០០៦៩ | មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការសម្ដេចតេជោ ហ៊ុន សែន ៣១៧គូលេនសៀមរាប |
| ១៣-វរសេនីយ៍ឯក | ងួន វ៉ាន់ណារ៉ា | អត្តលេខ២០២៥៤១៤ | អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ |
| ១៤-វរសេនីយ៍ឯក | ប៊ូ គង់ | អត្តលេខ២០៥០៣៨៩ | មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការសម្ដេចតេជោ ហ៊ុន សែន ៣១៧គូលេនសៀមរាប |
| ១៥-វរសេនីយ៍ឯក | គឹម នី | អត្តលេខ២០១៣៩៩៣ | មជ្ឈមណ្ឌលបំប៉នសុខភាពយោធិនពិការ៣១៧កោះស្លា |
| ១៦-វរសេនីយ៍ឯក | អំ រិត | អត្តលេខ២០២៤៩៤៩ | មជ្ឈមណ្ឌលបំប៉នសុខភាពយោធិនពិការ៣១៧កោះស្លា |
| ១៧-វរសេនីយ៍ឯក | ប្រាក់ សម | អត្តលេខ២០១៩៨១៣ | នាយកដ្ឋានបញ្ជូនសារ (មរណៈ) |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលុបឈ្មោះ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣ /១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤ /២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១** :_

ត្រូវបានលុបឈ្មោះ នាយទាហានចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ វរសេនីយ៍ឯក **ហ៊ឹម ហុកលេខ** អត្តលេខ ០៦១៣០៨ ជំនួយការ ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯល ម៉ាន់សារ៉ាត** រដ្ឋលេខាធិការ ក្រសួងការពារជាតិ ដោយមិនគោរពច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងបទវិន័យទូទៅសម្រាប់ កងយោធពលខេមរភូមិន្ទ ។

**មាត្រា២** :_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣**:_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦១០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .–**

ត្រូវបានដាក់លោក **សឹម ធីរយៈ** អត្តលេខ ១៧៥២១០០០៥៩ នៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យចូលនិវត្តន៍មុនអាយុកំណត់ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦។

**មាត្រា២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨២ សសរ

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៥៦ សសរ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- យោងតាមសំណូមពរចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងឯកឧត្ដម **ជាវ អានសាន** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសមាជិកគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ជំនួសឯកឧត្ដម **ភាន ច័ន្ទមេត្តា**។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៣ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២៧១ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)

- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)
- យោងតាមសំណូមពរចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ) ដូចខាងក្រោម៖

១- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៣- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៤- ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៥- ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អនុប្រធាន

៦- ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៧- ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៨- ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន សមាជិក

៩- លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិកា

១០- ឯកឧត្តម **ឌិត សុធា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១- ឯកឧត្តម **គង់ វិមាន** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១២- ឯកឧត្តមនាយឧត្តមសេនីយ៍ **ខឹមជា សាឃឿន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១៣- ឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ សមាជិក

១៤- ឯកឧត្តមសន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារផ្នែកសន្តិសុខ សមាជិក

១៥- ឯកឧត្តម **ប៉ាវ ហាមផាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារអត្តសញ្ញាណកម្ម សមាជិក

១៦- ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារភស្តុភារនិងហិរញ្ញវត្ថុ សមាជិក

១៧- ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារអន្តោប្រវេសន៍ សមាជិក

១៨- ឯកឧត្តម **ហ៊ឹម យ៉ាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារផ្នែកសណ្តាប់ធ្នាប់សាធារណៈនិងចរាចរណ៍ សមាជិក

១៩- ឯកឧត្តម **អ៊ុំ ម៉ារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារកិច្ចការរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ សមាជិក

២០- ឯកឧត្តម **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលការងារបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ សមាជិក

២១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ សមាជិកអចិន្ត្រៃយ៍

២២- ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សមាជិក

២៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ សុផាន់** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក សមាជិក

២៥- ឯកឧត្តមនាយឧត្តមសេនីយ៍ **សឹង សំណាង** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងអាកាស សមាជិក

២៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ផាត សុផានិត** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃក្រសួងមហាផ្ទៃ សមាជិក

២៧- ឯកឧត្តមនាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ សមាជិក

២៨- ឯកឧត្តមឧត្តមសេនីយ៍ឯក **ឡុប នេត** អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ សមាជិក

២៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ វាសនា** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ សមាជិក

៣០- ឯកឧត្តមឧត្តមនាវីឯក **ទៀ សុខា** មេបញ្ជាការកងទ័ពជើងទឹក សមាជិក

៣១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត សមាជិក។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

STATE SECRETARIAT OF BORDER AFFAIRS

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**
លេខៈ ០២១/២៦ រកត.សសរ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 3832
ថ្ងៃទី 30 ខែ 07 ឆ្នាំ 26
ម៉ោង 9H 32

## សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តព្រះវិហារ
## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចលេខ១៦១ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ឡាវ
- បានឃើញសេចក្តីសម្រេចលេខ១៦២ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ថៃ

- បានឃើញសេចក្ដីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្ដីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## **សម្រេច**

**ប្រការ១ ._**

ត្រូវបានទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនខេត្តព្រះវិហារ ចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **គីម រិទ្ធី** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- ឧត្តមសេនីយ៍ត្រី **ជាតិ ចាម** | នាយសេនាធិការរងយោធភូមិភាគទី៤ | អនុប្រធាន |
| ៣-លោក **ណុច ឧុធ្ធី** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **យ៉ុង គឹមហឿង** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥- ឧត្តមសេនីយ៍ទោ **ច័ន្ទ សុភ័ក្ត្រា** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ | សមាជិក |
| ៦-ឧត្តមសេនីយ៍ទោ **សួស សុខដារ៉ា** | ស្នងការនៃនគរបាលខេត្តព្រះវិហារ | សមាជិក |
| ៧- ឧត្តមសេនីយ៍ត្រី **ភង សៅគុណា** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៨- លោក **ពឹង ទ្រីដា** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៩- លោក **សំ លាងទ្រី** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- លោក **ចាប កុយ** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១១- លោក **ម៉ុម សុធ្ធារ៉ា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- លោក **ផាន់ សំអាង** | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ១៣- លោក **ម៉ប់ ធីរិត** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៤- លោក **ស៊ីន ចាន់រក្សា** | ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ១៥- លោក **សរ សាវេត** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១៦- លោក **មឿង សុគេន** | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១៧- លោក **ចិន ខន្តី** | អភិបាល នៃគណៈអភិបាលស្រុកជាំក្សាន្ត | សមាជិក |
| ១៨- លោក **ឃិត សុធារ៉ា** | អភិបាល នៃគណៈអភិបាលស្រុកឆែប | សមាជិក |
| ១៩- លោក **នាន់ ប៊ូនេត** | ប្រធានទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិអានសេះ | សមាជិក |
| ២០- វរសេនីយ៍ឯក **ឃួន ប៊ុនធឿន** | មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៧៩៣ | សមាជិក |
| ២១- វរសេនីយ៍ឯក **ហែម សារឿន** | មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៧៩៥ | សមាជិក |
| ២២- វរសេនីយ៍ឯក **មុយ ពុម្ភ** | មេបញ្ជាការវរសេនាតូចនគរបាលអន្តរាគមន៍ព្រំដែនគោក | សមាជិក |

| | | |
|---|---|---|
| ២៣- វរសេនីយ៍ឯក **សំវង្ស វិចិត្រ** | នាយប៉ុស្តិ៍ប្រកទ្វារព្រំដែនអន្តរជាតិអានសេះស្តីទី | សមាជិក |
| វរសេនីយ៍ទោ **រៀម ខេត** | មេបញ្ជាការវរសេនាតូចការពារព្រំដែនគោក នៃតំបន់ប្រតិបត្តិការសឹករងព្រះវិហារ | សមាជិក |
| ២៤- វរសេនីយ៍ត្រី **សំបូរ មុន្នីសី** | មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ១០៥ | សមាជិក។ |

**ប្រការ២ .-**

អនុគណៈកម្មការព្រំដែនខេត្តព្រះវិហារ មានភារកិច្ចដូចបានកំណត់នៅក្នុងសេចក្តីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង។

**ប្រការ៣ .-**

សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

STATE SECRETARIAT OF BORDER AFFAIRS

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**
លេខៈ ០២២/២៦ រកព. សសរ

ទីស្ដីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 3833
ថ្ងៃទី 30 ខែ 07 ឆ្នាំ 26
ម៉ោង 9H34

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តស្ទឹងត្រែង**
**រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្ដីសម្រេចលេខ១៦១ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ឡាវ
- បានឃើញសេចក្ដីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្ដីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន/

## សម្រេច

**ប្រការ១ .-**

ត្រូវបានទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនខេត្តស្ទឹងត្រែង ចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សរ សុពុទ្ធា** | អភិបាលនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- ឧត្តមសេនីយ៍ទោ **ហួត សុវណ្ណា** | មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី១ | អនុប្រធាន |
| ៣- លោក **ស្រ៊ន សំឬទ្ធី** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **ញ៉ៀម វណ្ណាយុត្តិ** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥- ឧត្តមសេនីយ៍ទោ **អូត ស៊ីវុត្ថា** | ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្ត | សមាជិក |
| ៦- ឧត្តមសេនីយ៍ត្រី **គន តៃ** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង | សមាជិក |
| ៧- ឧត្តមសេនីយ៍ត្រី **សេខ សុភាព** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង | សមាជិក |
| ៨- ឧត្តមសេនីយ៍ត្រី **នូ ហួរ** | ស្នងការរងទទួលបន្ទុកវរព្រំដែន ៧០១ | សមាជិក |
| ៩- លោក **ខេង ឧិត្យសីហា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១០- លោក **អ៊ួន សុខា** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ១១- លោក **គីម ពិសិដ្ឋ** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ១២- លោក **ទុំ នីរ៉ូ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ១៣- លោក **ស្រេខ ជាហេខ** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១៤- លោក **លំ សេរីគុត** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ១៥- លោក **ព្រំ ចាន់ថា** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១៦- លោក **សរ គឹមណាត** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | សមាជិក |
| ១៧- លោកស្រី **ញ៉ៀម សុមាលី** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |
| ១៨- លោក **សន សារឿន** | អភិបាលនៃគណៈអភិបាលស្រុកសៀមប៉ាង | សមាជិក |
| ១៩- លោក **ផាន់ យុត** | អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ | សមាជិក |
| ២០- លោក **ស្វាយ ពុទ្ធារ៉ា** | ជំនួយការទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល | សមាជិក |
| ២១- វរសេនីយ៍ឯក **អ៊ូច មាន** | នាយកប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល | សមាជិក |
| ២២- វរសេនីយ៍ទោ **ព្រំ សុផា** | នាយករងសេនាធិការតំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង | សមាជិក |

| | | | |
|---|---|---|---|
| ២៣- វរសេនីយ៍ទោ **ហ៊ុយ ធីតា** | មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៧០១ | សមាជិក។ |

**ប្រការ២ .-**

អនុគណៈកម្មការព្រំដែនខេត្តស្ទឹងត្រែង មានភារកិច្ចដូចបានកំណត់នៅក្នុងសេចក្ដីសម្រេច លេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្ដីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង។

**ប្រការ៣ .-**

សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ០០៥ ប្រក. កសក

# ប្រកាស
## ស្តីពី
## រូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងដើម្បីប្រើជាផ្លូវការក្នុងដំណើរការការងាររបស់ខ្លួន ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។



អាសយដ្ឋានលេខ ២០០ បហោវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៣ ០០៨ អ៊ីម៉ែល: info@maff.gov.kh
Phone: (023) 723 008 Email: info@maff.gov.kh Website: http://www.maff.gov.kh

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖

១-អគ្គលេខាធិការដ្ឋាន។

២-អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ។

៣-អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ។

៤-អគ្គនាយកដ្ឋានជលផល។

៥-អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ។

៦-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

## ជំពូកទី២
## ការប្រើរូបសញ្ញានិងត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ប្រការ៣ .-**

អគ្គលេខាធិការដ្ឋាននិងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៣
## រូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ

**ប្រការ៤ .-**

រូបសញ្ញារបស់អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

**១-សណ្ឋានរូបផ្នែកខាងក្រៅ**

- ធ្នូរង្វង់ផ្នែកខាងឆ្វេងនិងខាងស្តាំ រចនាដោយកួរស្រូវពណ៌មាស តំណាងឱ្យផលិតផលស្បៀងដែលមានដំណាំស្រូវជាមូលដ្ឋាន និងជាមរតកកសិកម្មកម្ពុជាតាំងពីសម័យអង្គរ
- ធ្នូរង្វង់ផ្នែកខាងក្រោម រចនាដោយកងចក្រពណ៌មាស តំណាងឱ្យគ្រឿងយន្តនិងឧបករណ៍កសិកម្ម និងការធ្វើទំនើបកម្មផលិតកម្មដំណាំ
- នៅផ្នែកខាងលើកងចក្ររចនាដោយកម្រងបូមានសណ្ឋាននិងពណ៌ដូចទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា តំណាងឱ្យឯកសារគោលនយោបាយ ច្បាប់ បទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានា
- នៅពីលើបូ មានប៉ាក់អក្សរពុម្ពពណ៌ស "**អ ន ក**" តំណាងឱ្យអគ្គនាយកដ្ឋានក្សេត្រសាស្ត្រ។

**២-សណ្ឋានរូបផ្នែកខាងក្នុង**

- ផ្នែកខាងលើ វិលេចដោយរូបភាពផ្ទៃមេឃពណ៌ខៀវនិងពពកពណ៌សដែលតំណាងឱ្យខ្យល់អាកាសនិងពន្លឺព្រះអាទិត្យសម្រាប់ឱ្យរុក្ខជាតិធ្វើរស្មីសំយោគដើម្បីជំរុញការលូតលាស់ និងផ្តល់ផ្កាផ្លែ
- នៅចំកណ្តាលរង្វង់ មានរូបដៃទ្រុក្ខជាតិ តំណាងឱ្យធនធានមនុស្សដែលខិតខំអភិវឌ្ឍនិងអនុវត្តបច្ចេកទេសដាំដុះ ថែទាំ និងការពារដំណាំឱ្យទទួលភោគផលល្អ
- នៅចន្លោះកណ្តាលរូបដៃទាំងពីរ មានដើមរុក្ខជាតិកំពុងដុះលូតលាស់ល្អ តំណាងឱ្យមុខដំណាំគ្រប់ប្រភេទនៃអនុវិស័យដំណាំកម្ពុជា
- នៅផ្នែកកណ្តាលខាងក្រោមរូបដៃនិងដើមរុក្ខជាតិ វិលេចដោយផ្ទៃវាលពណ៌បៃតង តំណាងឱ្យដីស្រែចម្ការច្បារដំណាំគ្រប់ប្រភេទនៃអនុវិស័យដំណាំ

២៧

- នៅផ្នែកខាងឆ្វេងមានធ្នូចំណិតរង្វង់ពណ៌ខៀវ តំណាងឱ្យធនធានទឹកសម្រាប់ស្រោចស្រព ដំណាំ រីឯនៅផ្នែកខាងស្តាំមានធ្នូចំណិតរង្វង់ពណ៌ត្នោត តំណាងឱ្យផ្ទៃធរណីដែលមានដីជាតិ សម្រាប់បង្កបង្កើនផល។

**ប្រការ៥ .-**

ត្រារបស់អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ មានសណ្ឋានដូចខាងក្រោម៖

**១-សណ្ឋានរូបផ្នែកខាងក្រៅ**

- មានវ័ណ្ឌពាងរង្វង់មូល២(ពីរ)ជាន់
- នៅចន្លោះវ័ណ្ឌខាងក្រៅនិងវ័ណ្ឌខាងក្នុង ផ្នែកខាងលើមានឆ្លាក់រំលេចអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌ និងនៅចន្លោះអក្សរទាំង២(ពីរ)នេះមានរូបផ្កាចន្ទន៍អមសងខាង។

**២-សណ្ឋានរូបផ្នែកខាងក្នុង**

- មានវ័ណ្ឌពាងរង្វង់មូល១(មួយ)ជាន់
- ក្នុងវ័ណ្ឌពាងរង្វង់មូលនេះ ផ្នែកខាងលើមានរំលេចរូបផ្ទៃដីស្រែចម្ការច្បារដំណាំ ពីក្រោមរូបដៃទ្រវុត្ថជាតិដែលមានស្លឹកចំនួន៥(ប្រាំ) រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌផ្នែកខាងក្នុង។

**ប្រការ៦ .-**

គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

## ជំពូកទី៤

## រូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

**ប្រការ៧ .-**

រូបសញ្ញារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងរង្វង់ផ្ទៃពណ៌មាស ដែលមានរំលេចរូបមែកឈើមានស្លឹកបី ជានិមិត្តរូបដំណាំចំណីសត្វ និងមានរូបសត្វទាំង៩(ប្រាំបួន)ស្ថិតក្នុងផ្ទៃពណ៌បៃតង ពណ៌ផ្ទៃមេឃ ជានិមិត្តរូបផលិតកម្មសត្វ វាលស្មៅ ចិញ្ចឹមសត្វ និងសក្តានុពលនៃការអភិវឌ្ឍការចិញ្ចឹមសត្វ រីឯផ្នែកខាងក្រោមមានរូបបូពណ៌ក្រហមនិងខៀវដាក់ពាសនៅលើរង្វង់ផ្ទៃពណ៌មាសនិងរំលេចតួអក្សរ "**អ ស ផ ស**" តំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- នៅចំកណ្តាលនៃផ្ទៃរង្វង់ មាន៖
  - មានផ្ទាំងពណ៌ទឹកប៊ិកបីជ្រុង ជានិមិត្តរូបចំណងទាក់ទងរវាងសត្វ ភ្នាក់ងារចម្លងជំងឺ និងបរិស្ថាន រីឯអក្សរវីធំ " V " ពណ៌មាសជានិមិត្តរូបបសុពេទ្យ
  - រូបពស់ពណ៌មាស ជានិមិត្តរូបបសុឱសថ និងរូបម្ពលពណ៌មាសដែលពស់រុំព័ទ្ធ ជានិមិត្តរូបនៃការការពារនិងព្យាបាលសត្វ
  - ផ្ទៃពណ៌ទឹកមាសនៅក្នុងរង្វង់មូលដែលផ្ទៃពណ៌ទឹកប៊ិក និមិត្តរូបចំណូលគ្រួសារនិងសេដ្ឋកិច្ចជាតិ។

**ប្រការ៨ .—**

ត្រារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ មានសណ្ឋានដូចខាងក្រោម៖

**១-សណ្ឋានរូបផ្នែកខាងក្រៅ**

- មានវណ្ណរាងរង្វង់មូល២(ពីរ)ជាន់
- នៅចន្លោះវណ្ណខាងក្រៅនិងវណ្ណខាងក្នុង ផ្នែកខាងលើមានឆ្លាក់រំលេចអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**" ស្របតាមសណ្ឋានកោងនៃវណ្ណ និងនៅចន្លោះពាក្យទាំង២(ពីរ)នេះមានរូបផ្កាចន្ទន៍អមសងខាង។

**២-សណ្ឋានរូបផ្នែកខាងក្នុង**

- មានវណ្ណរាងរង្វង់មូល១(មួយ)ជាន់
- ក្នុងវណ្ណរាងរង្វង់មូលនេះ មានរំលេចរូបដូចខាងក្រោម៖
  - ស្នូលខាងក្នុងមានរូបម្ជុលដែលមានរូបពស់រុំព័ទ្ធ ស្ថិតនៅចំណុចកណ្តាលអក្សរធំ "V" ក្នុងគំនូសរាងត្រីកោណនិងមានវណ្ណរាងរង្វង់មូលព័ទ្ធជុំវិញ
  - ព័ទ្ធជុំវិញស្នូល មានបណ្តុំចំណែកចំនួន១០(ដប់) ដែលមានរូបមែកឈើមានស្លឹកបីនិងមានរូបសត្វចំនួន៩(ប្រាំបួន) ដែលចាប់ពីឆ្វេងរូបមែកឈើមានស្លឹកបី មានរូបសត្វសេះ ចៀម មាន់ ជ្រូក គោ ក្របី ទា ពពែ និងសុនក
  - ផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**" ស្របតាមសណ្ឋានកោងនៃវណ្ណផ្នែកខាងក្នុង។

**ប្រការ៩ .—**

គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

## ជំពូកទី៥
## រូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានជលផល

**ប្រការ១០ .—**

រូបសញ្ញារបស់អគ្គនាយកដ្ឋានជលផល ត្រូវបានកំណត់ដូចខាងក្រោម៖

- ខាងលើមានកន្ទុយនាគរាជពីរព័ទ្ធគ្នាជាក្បាច់ភ្ញីពណ៌មាស
- ខាងក្រោមមានផ្ទៃពណ៌ក្រហម និងផ្នែកចុងសងខាងមានពីរផ្ទត់រំលេចដោយតួអក្សរ "**អ ន ជ**" ពណ៌ស តំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានជលផល
- ផ្នែកសងខាងមានខ្លួននិងក្បាលនាគរាជចំនួន២(ពីរ)ពណ៌មាសបែរមុខចេញក្រៅ
- ផ្នែកលើមានពណ៌ផ្ទៃមេឃរំលេចទៅដោយរូបត្រីចំនួន២(ពីរ)ពណ៌ស និងរូបបង្កង១(មួយ)ក្បាលពណ៌មាសនៅចំកណ្តាល
- ផ្នែកកណ្តាលមានព្រៃលិចទឹកនិងព្រៃកោងកាងមានពណ៌បៃតងខ្ចី
- ផ្នែកក្រោមមានរូបទឹករលកចំនួន៧(ប្រាំពីរ)ពណ៌ខៀវទឹកប៊ិក ព័ទ្ធដោយទឹកសមុទ្រពណ៌ផ្ទៃមេឃដែលរំលេចដោយជាយពណ៌ស។

**ប្រការ១១ .–**

ត្រារបស់អគ្គនាយកដ្ឋានជលផល មានសណ្ឋានដូចខាងក្រោម៖

**១-សណ្ឋានរូបផ្នែកខាងក្រៅ**

- មានវ័ណ្ឌរាងរង្វង់មូល២(ពីរ)ជាន់
- នៅចន្លោះវ័ណ្ឌខាងក្រៅនិងវ័ណ្ឌខាងក្នុង ផ្នែកខាងលើមានឆ្លាក់រំលេចអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌ និងនៅចន្លោះពាក្យទាំង២(ពីរ)នេះមានរូបផ្កាចន្ទន៍អមសងខាង។

**២-សណ្ឋានរូបផ្នែកខាងក្នុង**

- មានវ័ណ្ឌរាងរង្វង់មូល១(មួយ)ជាន់
- ក្នុងវ័ណ្ឌរាងរង្វង់មូលនេះ មានរំលេចរូបដូចខាងក្រោម៖
  - ផ្នែកលើមានរំលេចរូបត្រីចំនួន២(ពីរ) និងរូបបង្កង១(មួយ) នៅចំកណ្តាល
  - ផ្នែកកណ្តាលមានព្រៃលិចទឹកនិងព្រៃកោងកាង
  - ផ្នែកក្រោមមានរូបទឹករលកចំនួន៧(ប្រាំពីរ) ព័ទ្ធដោយទឹកសមុទ្រ
  - ផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**អគ្គនាយកដ្ឋានជលផល**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌផ្នែកខាងក្នុង។

**ប្រការ១២ .–**

គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានជលផល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

## ជំពូកទី៦
## រូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ

**ប្រការ១៣ .–**

រូបសញ្ញារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ ត្រូវបានកំណត់ដូចខាងក្រោម៖

- វ័ណ្ឌខាងក្រៅផ្នែកខាងលើមានក្បាច់ភ្ញីទេសពណ៌មាសផុសឡើងអមសងខាងតួមកុដពណ៌មាសចម្រុះដោយពណ៌ក្រហមក្រមៅ ហើយផ្ទត់សំពត់ពណ៌មាសចម្រុះដោយពណ៌ក្រហមក្រមៅទ្រមកុដ
- វ័ណ្ឌខាងក្រៅផ្នែកខាងក្រោមពណ៌បៃតងចាស់រំលេចដោយតួអក្សរ "**អ ន ព**" ពណ៌មាស តំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ
- វ័ណ្ឌខាងក្រៅទាំងសងខាងក្រណាត់បូរមានផ្នត់បីថ្នាក់ ពណ៌ក្រហមក្រមៅ និងចុងជាយនីមួយៗរំលេចពណ៌មាស
- នៅចំកណ្តាលនៃសញ្ញាសម្គាល់ មានដើមឈើពណ៌មាសនិងកន្សោមស្លឹកបីត្រសុំពណ៌បៃតងចាស់ និងនៅប៉ែកខាងគល់ដើមឈើមានរូបញញួរត្រារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃចំនួន២(ពីរ)ដាក់ខ្វែងគ្នាជាប់នឹងដើមឈើ

- នៅសងខាងនិងខាងក្រោមដើមឈើកណ្តាលនៃសញ្ញាសម្គាល់មានផ្កាចន្ទន៍បែកជាវង្វង់ក្បាច់ភ្ញីស្លឹកកន្ទួតពណ៌មាស២(ពីរ) មានទម្រង់ជាស្នែងក្របី។

**ប្រការ១៤ .—**

ត្រារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ មានសណ្ឋានដូចខាងក្រោម៖

**១-សណ្ឋានរូបផ្នែកខាងក្រៅ**

- មានវ័ណ្ឌរាងវង្វង់មូល២(ពីរ)ជាន់
- នៅចន្លោះវ័ណ្ឌខាងក្រៅនិងវ័ណ្ឌខាងក្នុង ផ្នែកខាងលើមានឆ្លាក់រំលេចអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌ និងនៅចន្លោះពាក្យទាំង២(ពីរ)នេះមានរូបផ្កាចន្ទន៍អមសងខាង។

**២-សណ្ឋានរូបផ្នែកខាងក្នុង**

- មានវ័ណ្ឌរាងវង្វង់មូល១(មួយ)ជាន់
- ក្នុងវ័ណ្ឌរាងវង្វង់មូលនេះ ផ្នែកខាងលើមានមានរំលេចរូបដើមឈើនិងកន្សោមស្លឹកបីត្រសុំ និងមានរូបសត្វគោព្រៃឈរខាងមុខពីក្រោមដើមឈើនេះ រីឯផ្នែកខាងក្រោមមានឆ្លាក់រំលេចអក្សរ "**អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ**" ស្របតាមសណ្ឋានកោងនៃវ័ណ្ឌផ្នែកខាងក្នុង។

**ប្រការ១៥ .—**

គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

## ជំពូកទី៧
## ការប្រើរូបសញ្ញានិងត្រា

**ប្រការ១៦ .—**

រូបសញ្ញារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងប្រកាសនេះ ត្រូវបានប្រើដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់អង្គភាព
- ដាក់លើក្បាលលិខិត ឯកសារ និងលើស្រោមសំបុត្រផ្លូវការរបស់អង្គភាព
- ប្រើជាផ្លូវការក្នុងករណីផ្សេងទៀត។

ត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងប្រកាសនេះ ត្រូវប្រើលើលិខិតរដ្ឋបាល បែបបទរដ្ឋបាល លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារផ្លូវការផ្សេងទៀតស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការប្រើរូបសញ្ញានិងក្បាលលិខិតរបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

៦/៧

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**ប្រការ១៧ .–**

លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារផ្សេងទៀត ដែលមានប្រើរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មុនប្រកាសនេះ ត្រូវបន្តអនុវត្តរហូតដល់ផុតសុពលភាព។

**ប្រការ១៨ .–**

រូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកំពុងប្រើសព្វថ្ងៃ ត្រូវបន្តប្រើរហូតដល់មានរូបសញ្ញានិងត្រាថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ១៩ .–**

លិខិតពាក់ព័ន្ធដែលកំណត់អំពីរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានកៅស៊ូ អគ្គាធិការដ្ឋាន នាយកដ្ឋានកសិ-ឧស្សាហកម្ម និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានមុនប្រកាសនេះ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០ .–**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ០០៥ប្រក.កសក ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានកៀគ្រសាស្ត្រ

**១.គំរូរូបសញ្ញា**

២.គំរូត្រា

ត្រាមូលត្រូវបានកំណត់ខ្នាត៤១មិល្លីម៉ែត្រ

| រូបត្រាស្ថិតក្នុងពុម្ពសុវត្ថិភាព | រូបត្រាពេលប្រើប្រាស់ផ្លូវការ |
|---|---|
| | |

ឧបសម្ព័ន្ធទី២នៃប្រកាសលេខ០០៥ ប្រក.កសក ចុះថ្ងៃទី៦ ខែ មករា ឆ្នាំ២០២៦
ស្ដីពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

**១.គំរូរូបសញ្ញា**

**២.គំរូត្រា**

ត្រាមូលត្រូវបានកំណត់ខ្នាត៤១មិល្លីម៉ែត្រ

| រូបត្រាស្ថិតក្នុងពុម្ពសុវត្ថិភាព | រូបត្រាពេលប្រើប្រាស់ផ្លូវការ |
| --- | --- |
|  |  |

ឧបសម្ព័ន្ធទី៣នៃប្រកាសលេខ០០៥ ប្រក.កសក ចុះថ្ងៃទី៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានជលផល

**១.គំរូរូបសញ្ញា**




**២.គំរូត្រា**

ត្រាមូលត្រូវបានកំណត់ខ្នាត៤១មិល្លីម៉ែត្រ

| រូបត្រាស្ថិតក្នុងពុម្ពសុវត្ថិភាព | រូបត្រាពេលប្រើប្រាស់ផ្លូវការ |
|---|---|
|  |  |

ឧបសម្ព័ន្ធទី៤នៃប្រកាសលេខ០០៥ ប្រក.កសក ចុះថ្ងៃទី៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូរូបសញ្ញានិងត្រារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ

**១.គំរូរូបសញ្ញា**



**២.គំរូត្រា**

ត្រាមូលត្រូវបានកំណត់ខ្នាត៤១មិល្លីម៉ែត្រ

| រូបត្រាស្ថិតក្នុងពុម្ពសុវត្ថិភាព | រូបត្រាពេលប្រើប្រាស់ផ្លូវការ |
|---|---|
|  |  |

ឧបសម្ព័ន្ធទី៥នៃប្រកាសលេខ០០៥ ប្រក.កសក ចុះថ្ងៃទី៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីរូបសញ្ញានិងត្រារបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ការប្រើរូបសញ្ញានិងក្បាលលិខិតរបស់អង្គភាពចំណុះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក-ទម្រង់រៀបចំក្បាលលិខិត**

ទម្រង់ក្បាលលិខិត ត្រូវប្រើក្រដាសប្រភេទA4 មានគម្លាតដូចគំនូស និងត្រូវរៀបចំតាមចំណុចបង្ហាញដូចខាងក្រោម៖

១-អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Moul Light ទំហំអក្សរ១៣ និងអក្សរ "**ជាតិ សាសនា ព្រះមហាក្សត្រ**" ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Moul Light ទំហំអក្សរ១២ រីឯនៅខាងក្រោមត្រូវប្រើពុម្ពអក្សរTacteing ប្រភេទ " " ដែលមានទំហំអក្សរ២៣ និងត្រូវប្រើពណ៌ខៀវ។

២-អក្សរ "**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**" និង "**អគ្គនាយកដ្ឋាន**........." ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Moul Light ទំហំអក្សរ១១ រីឯនៅខាងក្រោមត្រូវប្រើពុម្ពអក្សរTacteingប្រភេទ " " ដែលមានទំហំ២១ និងត្រូវប្រើពណ៌ខៀវ។

៣-នៅទីតាំងចន្លោះកណ្តាលរវាងអក្សរបាវចនា និងអក្សរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រើរូបសញ្ញារបស់អង្គភាព ដែលមានទំហំអង្កត់ផ្ចិត៣សង់ទីម៉ែត្រ។

៤- ពុម្ពអក្សរសម្រាប់ការចុះលេខនិងកាលបរិច្ឆេទ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Siem Reap ទំហំអក្សរ១២និងត្រូវប្រើពណ៌ខៀវ។

**ខ-គំរូក្បាលលិខិត**

ក្បាលលិខិតរបស់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានដូចខាងក្រោម៖

១-ក្បាលលិខិតគំរូ១។

២-ក្បាលលិខិតគំរូ២។


១ ស.ម
២.១៨ ស.ម
គំរូ១
ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋាន........................
១ ស.ម
រូបសញ្ញា
៣ ស.ម
១ ស.ម
លេខ..............................
ថ្ងៃ... ..... ...... ..ខែ......... ..ឆ្នាំ...........ស័ក ព.ស.២៥៦..
រាជធានីភ្នំពេញ ថ្ងៃទី . . ខែ........... ឆ្នាំ២០....
វិមាត្រក្រដាសA4
វិមាត្រក្រដាសA4

១ ស.ម

២.១៨ ស.ម

គំរូ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គនាយកដ្ឋាន.....................

១ ស.ម

រូបសញ្ញា
៣ ស.ម

១ ស.ម

ទំហំក្រដាសA4

ទំហំក្រដាសA4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១០៦...ឧវឧន..កឧ..ប្រក........

ថ្ងៃ.អង្គារ....១រោច..... ខែផល្គុន.... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៧... ខែ.កុម្ភៈ.. ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៥៧៤/២២ ស.ត.ស.ព ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការបង្កើតរោងចក្រផលិតក្លួយ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៦ របស់ក្រុមហ៊ុន ជីនឡាយ ថេកស្តាយ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ជីនឡាយ ថេកស្តាយ ឯ.ក** **(JINLAI TEXTILES CO., LTD.)** តំណាងដោយលោកស្រី **FAN, ZHUXUAN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EJ5278279** ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ បង្កើតរោងចក្រផលិតក្លួយ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ (ក្បាលដីលេខC31-5 ភូមិពូធឿង សង្កាត់បិតត្រាំង និងភូមិស្មាច់ដែង សង្កាត់រាម ក្រុងកំពង់សោម ខេត្តព្រះសីហនុ) ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| កួយ | ១៣៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតកួយ ជីនឡាយ ថេកស្តាយ ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០១១ ឧវបន.ក ឧ.ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**បញ្ជូនជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
-រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹង ស៊ីនី

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី